# ជំនួយផ្នែកច្បាប់ឥន្ធធន្ទ

## លទ្ធភាពទទួលបានជំនួយផ្នែកច្បាប់សម្រាប់សហគមន៍អ្នកស្រលាញ់ភេទដូចគ្នា( LGBTIQ ) ក្នុងប្រទេសកម្ពុជា



VOICES for GENDER EQUALITY

គោលដៅយុត្តិធម៌ DESTINATION JUSTICE

# ជំនួយផ្នែកច្បាប់ឥន្ឌធន្វ

លទ្ធភាពទទួលបានជំនួយផ្នែកច្បាប់សម្រាប់សហគមន៍អ្នកស្រលាញ់ភេទដូចគ្នា

(LGBTIQ) ក្នុងប្រទេសកម្ពុជា

ការបោះពុម្ពផ្សាយនេះ ត្រូវបានធ្វើឡើងក្រោមជំនួយផ្នែកហិរញ្ញវត្ថុរបស់ សហភាពអឺរ៉ុប(EU) និង DanChurchAid(DCA) តាមរយៈគម្រោង សម្លេងសមភាពយេនឌ័រ។ ខ្លឹមសារនៅក្នុងរបាយការណ៍នេះ គឺជាទំនួលខុសត្រូវផ្តាច់មុខរបស់អង្គការគោលដៅយុត្តិធម៌ និងពុំឆ្លុះបញ្ចាំងពីទស្សនាទានរបស់ សហភាពអឺរ៉ុប(EU) និង DanChurchAid(DCA) ឡើយ។

ការស្រាវជ្រាវក្នុងរបាយការណ៍នេះ ត្រូវបានធ្វើឡើងនៅចន្លោះថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០១៨ ដល់ថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១៩ ដោយរបាយការណ៍បច្ចុប្បន្ននឹងចេញនៅខែកុម្ភៈ ឆ្នាំ ២០១៩ ។

© រក្សាសិទ្ធិគ្រប់យ៉ាងដោយអង្គការ គោលដៅយុត្តិធម៌ ឆ្នាំ ២០១៩ ។

ពុំមានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះ អាចត្រូវបានផលិតឡើងវិញ ចែកចាយ ឬបញ្ជូនក្នុងទម្រង់ណាមួយ ឬតាមមធ្យោបាយណាមួយ រួមទាំងការថតចម្លង ការថតសំឡេង ឬតាមវិធីសាស្ត្រអេឡិចត្រូនិច ឬវិធីសាស្ត្រមេកានិចដទៃទៀតណាមួយ ដោយពុំមានការការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអ្នកបោះពុម្ពផ្សាយឡើយ លើកលែងក្នុងករណីការដកស្រង់សម្តីខ្លីៗសំខាន់ៗ និងនៅក្នុងការប្រើប្រាស់មិនមែនបែបពាណិជ្ជកម្មដទៃទៀតមួយចំនួន ដែលអនុញ្ញាតដោយច្បាប់រក្សាសិទ្ធិបោះពុម្ពផ្សាយ។

## ព័ត៌មានអំពីអង្គការគោលដៅយុត្តិធម៌

បង្កើតឡើងតាំងពីឆ្នាំ២០១១ អង្គការគោលដៅយុត្តិធម៌ គឺជាអង្គការផ្លាស់ប្តូរសង្គមមួយ។ យើងគឺជាអ្នកធ្វើការផ្លាស់ប្តូរដែលជឿជាក់ថា យុត្តិធម៌ គឺជាគន្លឹះឆ្ពោះទៅរកសង្គមមួយប្រកបដោយសុខសន្តិភាព ជាពិសេសជាសង្គមមួយដែលប្រជាជនអាចដោះស្រាយបញ្ហារបស់ខ្លួន តាមរយៈមធ្យោបាយដែលឯករាជ្យ យុត្តិធម៌ និងមានតម្លាភាព ជាសង្គមមួយដែលច្បាប់ត្រូវបានបង្កើតឡើងដោយប្រជាជន ដើម្បីប្រជាជន ហើយប្រជាជនមានលទ្ធភាពប្រើប្រាស់ច្បាប់ដោយសេរី ហើយបន្ថែមលើនេះ គឺជាសង្គមមួយដែលមនុស្សគ្រប់រូបស្មើភាពគ្នា មិនថាពួកគេជានរណា គិតយ៉ាងណា ឬស្រលាញ់នរណាក្តី។

ដើម្បីអាចសម្រេចបានគោលដៅនេះ យើងធ្វើការងារយោងតាមគោលគំនិតដែលចាត់ទុកថា ផ្តើមចេញពីអ្វីដែលតូចៗ អាចធ្វើឲ្យអ្វីដែលធំរីកចម្រើនឡើង៖ គំនិតមួយត្រូវបានផ្លាស់ប្តូរ ព័ត៌មានមួយត្រូវបានបញ្ចេញមក ការអនុវត្តមួយត្រូវបានកែលម្អ។ យើងធ្វើយ៉ាងណាឱ្យគំនិតមានចលនាជានិច្ច យើងផ្តល់មធ្យោបាយ និងយើងធ្វើសកម្មភាពនៅពេលចាំបាច់។

តាមរយៈគម្រោងយុត្តិធម៌ឥន្ទធនូ អង្គការគោលដៅយុត្តិធម៌មានគោលបំណងជំរុញកិច្ចសន្ទនានៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ជាពិសេសក្នុងប្រទេសកម្ពុជា ស្តីពីនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញនូវទំនោរ

យេនឌ័រ និងលក្ខណៈភេទ (SOGIESC) និងផ្តល់មធ្យោបាយតស៊ូមតិដល់អ្នកធ្វើការផ្លាស់ប្តូរដើម្បីលើកកម្ពស់ និងការពារសិទ្ធិរបស់សហគមន៍ស្ត្រីស្រលាញ់ភេទដូចគ្នា បុរសស្រលាញ់ភេទដូចគ្នា អ្នកស្រលាញ់ភេទទាំងពីរ អ្នកប្តូរភេទ អ្នកអន្តរភេទ និងអ្នកមានភេទមិនកំណត់ច្បាស់ (LGBTIQ)។

**រូបភាពក្របមុខ៖** រូបថតផលិតដោយ Daily Beast អាចទាញយកបាននៅ http://compassq.com/index.php/2018/07/08/these-five-court-cases-could-change-the-future-of-lgbt-rights-2/rainbow-justice/ (11/02/2019)។

**សៀវភៅនេះអាចរកបាននៅ**

**ក្រុងភ្នំពេញ**

www.justice.cafe

# មាតិកា


អក្សរកាត់ និងនិយមន័យសព្ទ ........ 6
សេចក្តីផ្តើម ........ 7
សាវតារ ........ 7
គោលបំណង និងវិធីសាស្ត្រ ........ 9
សព្ទបច្ចេកទេស ........ 10
ការរកឃើញសំខាន់ៗ ........ 11
បរិបទ ........ 12
បញ្ហាផ្នែកច្បាប់ពាក់ព័ន្ធជាមួយ SOGIESC ដែលច្រើនកើតមានបំផុតក្នុងប្រទេសកម្ពុជា ........ 13
លទ្ធភាពទទួលបានជំនួយផ្នែកច្បាប់សម្រាប់សហគមន៍ LGBTIQ ក្នុងប្រទេសកម្ពុជា ........ 15
តម្រូវការទទួលបានមេធាវី ........ 15
ការយល់ដឹងអំពីជំនួយផ្នែកច្បាប់របស់សហគមន៍ LGBTIQ ........ 18
កម្រិតនៃទំនុកចិត្តរបស់អ្នកស្រលាញ់ភេទដូចគ្នា(LGBTIQ) ទៅលើយន្តការជំនួយផ្នែកច្បាប់ ........ 19
បទពិសោធន៍របស់អ្នកស្រលាញ់ភេទដូចគ្នា(LGBTIQ) ក្នុងការទៅរកជំនួយផ្នែកច្បាប់ ........ 20
សន្និដ្ឋាន ........ 21
ការប្រៀបធៀប៖ ការអនុវត្តល្អទូទាំងទ្វីបអាស៊ី ........ 23
ការផ្តួចផ្តើមគំនិតជំនួយផ្នែកច្បាប់សម្រាប់សហគមន៍ LGBTIQ ក្នុងតំបន់អាស៊ាន ........ 23
ការផ្តួចផ្តើមគំនិតជំនួយផ្នែកច្បាប់សម្រាប់សហគមន៍ LGBTIQ ក្នុងតំបន់អាស៊ីប៉ូស៊ីហ្វិក ........ 24
អនុសាសន៍សរុបសេចក្តី ........ 25
អនុសាសន៍ចំពោះរដ្ឋាភិបាលកម្ពុជា ........ 25
អនុសាសន៍ចំពោះក្រុមហ៊ុនមេធាវី និងមេធាវី ........ 25
អនុសាសន៍ចំពោះអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា ........ 26
អនុសាសន៍ចំពោះម្ចាស់ជំនួយ ........ 26
អនុសាសន៍ចំពោះសង្គមស៊ីវិល ........ 26
ឧបសម្ព័ន្ធទី ១ ៖ កម្រងសំណួរ ........ 27
សេចក្តីថ្លែងអំណរគុណ ........ 32

# អក្សរកាត់ និងនិយមន័យសព្ទ

| | |
|---|---|
| ADHOC | សមាគមសិទ្ធិមនុស្ស និងការអភិវឌ្ឍកម្ពុជា (NGO) |
| ASEAN | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| BAKC | គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| CCHR | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (NGO) |
| CSOs | អង្គការសង្គមស៊ីវិល |
| LAC | អង្គការជំនួយផ្នែកច្បាប់កម្ពុជា (NGO) |
| LGBTIQ | ស្ត្រីស្រលាញ់ស្ត្រីដូចគ្នា បុរសស្រលាញ់បុរសដូចគ្នា អ្នកស្រលាញ់ភេទទាំងពី អ្នកប្តូរភេទ អ្នកអន្តរភេទ និងអ្នកមានភេទមិនកំណត់ច្បាស់ |
| LICADHO | សម្ព័ន្ធភាពកម្ពុជាដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស (NGO) |
| LTC | មជ្ឈមណ្ឌលបណ្តុះបណ្តាលផ្នែកច្បាប់ |
| MoJ | ក្រសួងយុត្តិធម៌កម្ពុជា |
| MoWA | ក្រសួងកិច្ចការនារី |
| MRI | មីក្រូឥន្ទធនូអន្តរជាតិ (NGO) |
| OHCHR | ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RoCK | សហគមន៍ឥន្ទធនូកម្ពុជា (NGO) |
| SOGIESC | និន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញនូវទំនោរយេនឌ័រ និងលក្ខណៈភេទ |
| UNDP | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ |
| UPR | ការត្រួតពិនិត្យមើលជាសកលតាមពេលវេលាកំណត់ |

# សេចក្តីផ្តើម

## សាវតារ

នៅទូទាំងពិភពលោក សហគមន៍ស្ត្រីស្រលាញ់ស្ត្រី បុរសស្រលាញ់បុរស អ្នកស្រលាញ់ភេទទាំងពីរ អ្នកប្តូរភេទ អ្នកអន្តរភេទ និងអ្នកមានភេទមិនកំណត់ច្បាស់ (LGBTIQ) បានជំរុញការទទួលស្គាល់សិទ្ធិរបស់ខ្លួន តាមរយៈសកម្មភាពតស៊ូមតិ រួមទាំងនៅក្នុងវិស័យនយោបាយផងដែរ ប៉ុន្តែភាគច្រើនគឺតាមរយៈអំណាចតុលាការ។ មិនថានៅក្នុងសហរដ្ឋអាមេរិក ប្រទេសឥណ្ឌា បារាំង ឬតៃវ៉ាន់ក្តី ប្រព័ន្ធយុត្តិធម៌បានដើរតួនាទីដ៏សំខាន់ទាំងនៅក្នុងការបន្ធូរបន្ថយទោស ឬលុបចោលទោសព្រហ្មទណ្ឌចំពោះសកម្មភាពនៃការរួមភេទដោយមានការព្រមព្រៀងរវាងអ្នកស្រលាញ់ភេទដូចគ្នា ឬក៏មានការទទួលស្គាល់សិទ្ធិក្នុងការរៀបការសម្រាប់អ្នកមានភេទដូចគ្នា។

ក្នុងប្រទេសកម្ពុជា បើទោះបីជាមិនមានការដាក់ទោសទណ្ឌដោយផ្អែកលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញនូវទំនោរយេនឌ័រ និងលក្ខណៈភេទ (SOGIESC) របស់ពួកគេក្តី ប៉ុន្តែពុំមានការពារតាមផ្លូវច្បាប់ណាមួយឡើយ[1] ហើយក៏ពុំមានការបញ្ជ្រាបចំណេះដឹងអំពី LGBTIQ ឬ SOGIESC ជាក់លាក់តាមរយៈការបណ្តុះបណ្តាលដល់អ្នកប្រកបវិជ្ជាជីវៈផ្នែកតុលាការ ឬមន្ត្រីនគរបាលនោះដែរ។ យើងអាចនិយាយម្យ៉ាងទៀតថាប្រព័ន្ធយុត្តិធម៌មានភាពស្ងាត់ស្ងៀមនៅពេលនិយាយអំពីបុគ្គល LGBTIQ បើទោះបីជាសហគមន៍នេះ ជួបប្រទះនូវភាពងាយរងគ្រោះផ្នែកសង្គម និងសេដ្ឋកិច្ចយ៉ាងណាក្តី។ ជាលទ្ធផល បុគ្គល LGBTIQ ជារឿយៗតែងធ្លាក់ខ្លួនទៅក្នុងស្ថានភាពដ៏អាក្រក់ពេលដែលពួកគេព្យាយាមចូលទៅរកប្រព័ន្ធយុត្តិធម៌កម្ពុជា ដោយត្រូវពឹងផ្អែកលើអង្គការសង្គមស៊ីវិល (CSOs) តែមួយចំនួនតូចប៉ុណ្ណោះដែលកំពុងផ្តល់ជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ និង/ឬមេធាវីតិចតួចបំផុតដែលផ្តល់សេវាមិនយកកម្រៃ។[2]

អ្វីដែលធ្វើឱ្យបញ្ហាទាំងអស់នេះកាន់តែអាក្រក់ថែមទៀត នោះគឺការថមថយអ្នកផ្តល់ជំនួយ ដែលជាលទ្ធផលធ្វើឱ្យមូលនិធិកាន់តែថយចុះសម្រាប់អង្គការសង្គមស៊ីវិល ក្នុងការផ្តល់សេវាជំនួយផ្នែកច្បាប់។ ក្នុងឆ្នាំ ២០១៧ មានមេធាវីជំនួយផ្នែកច្បាប់ត្រឹមតែ ៣៧ នាក់ប៉ុណ្ណោះ បម្រើការងារឱ្យអង្គការសង្គមស៊ីវិលចំនួន ១៥ ដែល

---

[1] "Being LGBT in Asia: Cambodia Country Report", United Nations Development Programme and United States Agency for International Development, 2014, p.29, អាចបើកមើលបាននៅ http://www.asia-pacific.undp.org/content/dam/rbap/docs/Research%20&%20Publications/hiv_aids/rbap-hhd-2014-blia-cambodia-country-report.pdf (បើកមើលចុងក្រោយនៅថ្ងៃទី ២១ ខែមករា ឆ្នាំ ២០១៩)។

[2] "Achieving Justice for Gross Human Rights Violations in Cambodia: Baseline Study", International Commission of Jurists (ICJ), October 2017, p. 22, អាចបើកមើលបាននៅ http://www.refworld.org/pdfid/5a212f144.pdf (បើកមើលចុងក្រោយនៅថ្ងៃទី ២៤ ខែមករា ឆ្នាំ ២០១៩)។

មានចំនួនតិចជាងឆ្នាំ ២០០៦ ចំនួន ៥៣% ។[3] ស្រដៀងគ្នានេះដែរ ជំនួយផ្នែកច្បាប់ឧបត្ថម្ភដោយរដ្ឋ គឺនៅមានកម្រិតកំណត់ដូចគ្នានេះដែរ ដោយថវិកានាពេលបច្ចុប្បន្នដែលគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (BAKC)បានទទួល អាចគ្របដណ្តប់លើការផ្តល់ហិរញ្ញប្បទានចំពោះសំណុំរឿងតែ ៤០% ប៉ុណ្ណោះ (២០០០ សំណុំរឿងក្នុងចំណោមសំណើសុំជំនួយផ្នែកច្បាប់ចំនួន ៥០០០ សំណុំរឿង)។[4] ថ្វីបើក្រសួងយុត្តិធម៌កម្ពុជា (MoJ)ជាស្ថាប័នដែលទទួលថវិកាជំនួយផ្នែកច្បាប់សាធារណៈជារៀងរាល់ឆ្នាំ ដែលត្រូវបានចាត់តាំងដោយរាជរដ្ឋាភិបាលកម្ពុជា (RGC)ក្តី តែថវិកានេះត្រូវបានបញ្ជូនទៅឱ្យគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា(BAKC)ដើម្បីអនុវត្តការងារ ដោយហេតុថា BAKC ជាអ្នកទទួលខុសត្រូវក្នុងការផ្តល់ប្រាក់ចំណូលដល់មេធាវីដែលការពារជនក្រីក្រ[5] ដោយការមានមេធាវីតំណាងដែលច្បាប់តម្រូវឲ្យមានសម្រាប់សំណុំរឿងព្រហ្មទណ្ឌពាក់ព័ន្ធជាមួយបទឧក្រិដ្ឋ ឬបទមជ្ឈិម។[6] ក្នុងឆ្នាំ ២០១៨ ការិយាល័យមេធាវីមួយដែលផ្តល់សេវាមេធាវីឥតគិតថ្លៃក្នុងប្រទេសកម្ពុជាត្រូវបានបង្កើតឡើង ក្នុងក្តីសង្ឃឹមថានឹងអាចជំរុញទឹកចិត្តដល់មេធាវីកម្ពុជាដ៏ទៃទៀត ឱ្យទទួលយកសំណុំរឿងដោយស្ម័គ្រចិត្តផងដែរ។[7]

ក្រសួងយុត្តិធម៌ ទទួលស្គាល់ថា ជំនួយផ្នែកច្បាប់នៅកម្ពុជាត្រូវតែធ្វើការកែលម្អ ហើយដោយមានការគាំទ្រពី ការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា (OHCHR-Cambodia) បច្ចុប្បន្នក្រសួងកំពុងធ្វើសេចក្តីព្រៀងច្បាប់ថ្មីមួយស្តីពីជំនួយផ្នែកច្បាប់ ដែលនឹងត្រូវអនុម័តនាពេលឆាប់ៗ។ ស្របពេលជាមួយគ្នានេះដែរ ថវិកាជំនួយផ្នែកច្បាប់សាធារណៈ មានការកើនឡើងបន្ថែមទៀតចំនួន ៣០០ លានរៀល (៧៥ ០០០ ដុល្លាអាមេរិក) ជាហេតុធ្វើឱ្យថវិកាសរុបសម្រាប់ឆ្នាំ ២០១៩ មានទឹកប្រាក់ ១២០០ លានរៀល (៣០០ ០០០ ដុល្លាអាមេរិក) យោងតាមការឱ្យដឹងរបស់ក្រសួងយុត្តិធម៌[8] ដោយបានកត់សម្គាល់ថា ទឹកប្រាក់ចំនួន

---

[3] Kai Hauerstein, Assessment Report: Assessing the provision of legal aid and proposing policy recommendations, Final Draft, June 2018, pp. 51, 59.

[4] Kai Hauerstein, Assessment Report: Assessing the provision of legal aid and proposing policy recommendations, Final Draft, June 2018, p. 47.

[5] ច្បាប់ស្តីពីគណៈមេធាវី មាត្រា ២៩ ឆ្នាំ១៩៩៥ https://www.wto.org/english/thewto_e/acc_e/khm_e/WTACCKHM3A3_LEG_50.pdf (បើកមើលចុងក្រោយនៅថ្ងៃទី ២៤ ខែមករា ឆ្នាំ ២០១៩)។

[6] Annotated Cambodian Code of Procedure, Annotations to ECCC and select International Jurisprudence, Article 301, 2014, អាចបើកមើលបាននៅ http://cambodia.ohchr.org/~cambodiaohchr/sites/default/files/Annotated%20Cambodian%20Code%20of%20Criminal%20Procedure%20%5BEN%5D%20%5BMaster%20-%20Final%5D.pdf (បើកមើលចុងក្រោយនៅថ្ងៃទី ១៧ ខែកម្ភៈ ឆ្នាំ ២០១៩)។

[7] សូមមើល Pro Bono & Advisory Law Group at https://twitter.com/probonocambodia (បើកមើលចុងក្រោយនៅថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ ២០១៩)។

[8] Voun Dara, "Legal aid for kingdom's vulnerable", The Phnom Penh Post, 10 December 2018, អាចបើកមើលបាននៅ https://www.phnompenhpost.com/national/legal-aid-kingdoms-vulnerable (បើកមើលចុងក្រោយនៅថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១៩)។

៤០០ ០០០ រៀល (១០០ ដុល្លាអាមេរិក) ត្រូវបានផ្តល់ឱ្យសម្រាប់មួយសំណុំរឿង។ បន្ថែមលើនេះទៀត និស្សិតមេធាវីម្នាក់ៗ ដែលចូលមកក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលផ្នែកច្បាប់ (LTC) នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា(BAKC) ចាំបាច់ត្រូវបង់សេវាចំនួន ៨ លានរៀល (២ ០០០ ដុល្លាអាមេរិក) ដោយក្នុងនោះទឹកប្រាក់ មួយភាគបួន ត្រូវចាត់ទៅឱ្យមូលនិធិជំនួយផ្នែកច្បាប់។ ជាចុងក្រោយ ក្រសួងកិច្ចការនារី (MoWA) កំពុងគ្រោងចាត់ថវិកាដើម្បីផ្តល់ជំនួយផ្នែកច្បាប់ដល់កុមារី និងក្មេងស្រីងាយរងគ្រោះ ថ្វីបើពុំទាន់មានការប្រកាសជាសាធារណៈនៅឡើយ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ។

ក្នុងចំណោមទិន្នន័យប្រមូលបានតាមរយៈការស្រាវជ្រាវនេះ (ការសម្ភាសន៍ និងទិន្នន័យ) យើងបានប៉ាន់ប្រមាណថា បន្ទុកសំណុំរឿងនាពេលបច្ចុប្បន្នដែលបាននាំមកនៅចំពោះមុខតុលាការកម្ពុជា គឺពាក់ព័ន្ធជាពិសេសចំពោះបញ្ហាផ្នែកច្បាប់របស់ SOGIESC មានចំនួន ៣០ សំណុំរឿង។

## គោលបំណង និងវិធីសាស្ត្រ

នៅត្រង់ចំណុចប្រសព្វនៃគម្រោងធំៗទាំងពីររបស់អង្គការគោលដៅយុត្តិធម៌ (DJ) ក្នុងប្រទេសកម្ពុជា គម្រោងយុត្តិធម៌ឥន្ទធនូ (Rainbow Justice) និងគម្រោងបញ្ហាយុត្តិធម៌ (Justice Matters) របាយការណ៍ដែលមានចំណងជើងថា **ជំនួយផ្នែកច្បាប់ឥន្ទធនូ** (របាយការណ៍) របស់យើងនាពេលនេះ ធ្វើការវិភាគយ៉ាងសព្វជ្រុងជ្រោយលើកម្រិតនៃលទ្ធភាពទទួលបានជំនួយផ្នែកច្បាប់របស់អ្នកស្រលាញ់ភេទដូចគ្នា(LGBTIQ) ក្នុងប្រទេសកម្ពុជា។ របាយការណ៍នេះ ចងក្រងជាឯកសារអំពីក្របខ័ណ្ឌការងារផ្នែកច្បាប់ផង និងតថភាពជាក់ស្តែងដែលកើតមានទូទាំងប្រទេសផង។

របាយការណ៍នេះ មានបំណងលើកកំពស់កិច្ចសន្ទនា ដើម្បីកែលម្អលទ្ធភាពទទួលបានសេវាជំនួយផ្នែកច្បាប់របស់អ្នកស្រលាញ់ភេទដូចគ្នា ដែលត្រូវការជំនួយផ្នែកច្បាប់។ ដោយឡែករបាយការណ៍នេះ សង្ឃឹមថានឹងអាចផ្តល់ជាមធ្យោបាយសម្រាប់ អង្គការសង្គមស៊ីវិល មេធាវី និងស្ថាប័នកម្ពុជា ដើម្បីសម្រេចបានការកែលម្អដូចបានលើកឡើងខាងលើ។ ដើម្បីសម្រេចបានគោលដៅនេះ របាយការណ៍ផ្តល់អនុសាសន៍ជាក់លាក់ ក៏ដូចជាអនុសាសន៍ទូទៅសម្រាប់អង្គការសង្គមស៊ីវិល មេធាវី និងស្ថាប័នកម្ពុជានានា ឱ្យពិចារណានៅពេលផ្តល់ការជួយជ្រោមជ្រែងដល់អ្នកស្រលាញ់ភេទដូចគ្នា ពេលចូលទៅរកប្រព័ន្ធយុត្តិធម៌ក្នុងប្រទេសកម្ពុជា។

ការអង្កេតជាមូលដ្ឋាននៃរបាយការណ៍នេះ គឺការស្ទាបស្ទង់មតិមួយដែលបានធ្វើឡើងតាមប្រព័ន្ធអនឡាញ និងដោយជួបផ្ទាល់ (សូមមើលឧបសម្ព័ន្ធទី ១ អំពីកម្រងសំណួរ) ។ ចម្លើយតបចំពោះកម្រងសំណួរនេះ ត្រូវបានយកមកវិភាគ ដោយពិចារណាទៅលើក្រុមអាយុ តំបន់រាជធានី/តំបន់តាមខេត្ត និង SOGIESC ។ អ្នកស្រលាញ់ភេទ

ដូចគ្នាចំនួន ៩៦ នាក់ (អ្នកតំណាងប្រជាសាស្ត្រកម្ពុជាក្នុងន័យស្តីពីក្រុមអាយុ និងតំបន់រស់នៅ) បានឆ្លើយតបចំពោះការស្ទាបស្ទង់មតិ ចំណែកអ្នកផ្តល់ព័ត៌មានគន្លឹះចំនួន ១៤ នាក់ ត្រូវបានសម្ភាសយ៉ាងស៊ីជម្រៅ។ អ្នកផ្តល់បទសម្ភាសន៍ទាំងអស់នេះ ត្រូវបានសួរសំណួរបើកប្រហាក់ប្រហែលគ្នាដែលត្រូវបានផ្តល់ជូនដល់ពួកគាត់ជាមុន និងបានកែសម្រួលទៅតាមស្ថានភាពជាបុគ្គល និងស្ថានភាពស្ថាប័នរបស់ពួកគេ។ រាល់ការសម្ភាសន៍ទាំងអស់ ត្រូវបានថតសំឡេង។ អ្នកផ្តល់ការសម្ភាសន៍បានយល់ព្រមឱ្យសម្ភាសន៍ និងយល់ព្រមឱ្យធ្វើការបោះពុម្ពផ្សាយព័ត៌មានដែលបានផ្តល់ឱ្យនៅក្នុងផ្នែកពាក់ព័ន្ធនៃរបាយការណ៍នេះ។

កិច្ចពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ក៏ត្រូវបានធ្វើឡើងកាលពីថ្ងៃ អង្គារ ទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៩ ដើម្បីបង្ហាញការរកឃើញបឋមរបស់ការស្រាវជ្រាវនេះ និងដើម្បីទទួលបានយោបល់ត្រឡប់ផ្នែកលើព័ត៌មានត្រឹមត្រូវព្រមទាំងអនុសាសន៍ពីអ្នកឯកទេសចំនួន ៨ នាក់ ក្នុងវិស័យ SOGIESC / យេនឌ័រ និង/ឬជំនួយផ្នែកច្បាប់។

## សព្ទបច្ចេកទេស

**ជំនួយផ្នែកច្បាប់៖** អាចកំណត់និយមន័យយ៉ាងសាមញ្ញថា ជាការទូទាត់ប្រាក់ពីប្រភពមូលនិធិសាធារណៈដែលត្រូវបានផ្តល់ឱ្យដើម្បីជួយបង់ថ្លៃការផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬដំណើរការនីតិវិធីសម្រាប់ជនទាំងឡាយណា ដែលត្រូវការមេធាវី ហើយពុំមានលទ្ធភាពអាចរកមេធាវីបានតាមវិធីដទៃ"។

**LGBTIQ ៖** ជាអក្សរកាត់ត្រូវបានប្រើប្រាស់ ដើម្បីកំណត់អត្តសញ្ញាណសហគមន៍មានភេទមិនកំណត់ជាក់ច្បាស់ ដែលមានភាពខុសៗគ្នាទូទាំងប្រទេសកម្ពុជា និងខុសៗគ្នារវាងអង្គការសង្គមស៊ីវិល និងបុគ្គលនានា។ ដើម្បីឱ្យមានភាពស៊ីសង្វាក់គ្នា របាយការណ៍នេះ សូមប្រើប្រាស់អក្សរកាត់ "LGBTIQ" ក្នុងន័យទូលាយ ដើម្បីគ្របលើអត្តសញ្ញាណផ្សេងៗជាច្រើនរបស់សហគមន៍អ្នកមានភេទមិនកំណត់ច្បាស់កម្ពុជា លើកលែងតែក្នុងករណីដែលប្រភពដកស្រង់ព័ត៌មាន ប្រើប្រាស់អក្សរកាត់ផ្សេងពីនេះ។

**SOGIESC ៖** តាមទម្លាប់កន្លងមក "SOGIE" ត្រូវបានប្រើប្រាស់ ដើម្បីសំដៅលើនិន្នាការភេទ (SO) អត្តសញ្ញាណយេនឌ័រ (GI) និងការបង្ហាញនូវទំនោរយេនឌ័រ(E) ។ ប៉ុន្តែដោយមានការយល់ដឹងរីកសន្ធឹមៗ ស្តីពីភាពចម្រុះគ្នានៃអត្តសញ្ញាណក្នុងសហគមន៍អ្នកស្រលាញ់ភេទដូចគ្នា(LGBTIQ)ក្នុងប្រទេសកម្ពុជា របាយការណ៍នេះសូមប្រើប្រាស់សព្ទ SOGIESC ក្នុងន័យទូលាយបន្ថែមទៀតជំនួសវិញ ដោយសារពាក្យនេះ ក៏រួមមានសញ្ញាណស្តីពីលក្ខណៈភេទ(SC) ផងដែរ។

## ការរកឃើញសំខាន់ៗ

ការរកឃើញសំខាន់ៗ មួយចំនួនរបស់របាយការណ៍នេះ រួមមាន៖

១. **សហគមន៍ LGBTIQ ក្នុងប្រទេសកម្ពុជា ខ្វះចំណេះដឹងយ៉ាងទូលំទូលាយ** អំពីរបៀប និងកន្លែងដែលពួកគេអាចមានលទ្ធភាពទៅរកមេធាវី នៅពេលពួកគេជួបប្រទះបញ្ហាការរើសអើង និង/ឬ បញ្ហាផ្លូវច្បាប់

២. ជាទូទៅ និងនៅពេលដែលពាក់ព័ន្ធអ្នកស្រលាញ់ភេទដូចគ្នា(LGBTIQ) ភាគច្រើនដែលបានស្ទាបស្ទង់មតិ **មានអារម្មណ៍ថា មានទំនុកចិត្តក្នុងការបញ្ជាក់អំពី SOGIESC របស់ខ្លួន ប្រាប់ទៅមេធាវីរបស់ខ្លួន**

៣. **មានការយល់ដឹងកម្រិតទាបស្តីពីទស្សនាទានជំនួយផ្នែកច្បាប់**ក្នុងចំណោមសហគមន៍ LGBTIQ ក្នុងប្រទេសកម្ពុជា អមជាមួយនឹងការទទួលបានព័ត៌មានពាក់ព័ន្ធជាមួយជំនួយផ្នែកច្បាប់នូវមានកម្រិតទាប និងជាលទ្ធផលធ្វើឱ្យមានការមិនទុកចិត្តចំពោះមេធាវី ដែលផ្តល់ជំនួយផ្នែកច្បាប់

៤. ជាងពាក់កណ្តាលនៃអ្នកស្រលាញ់ភេទដូចគ្នា(LGBTIQ)ដែលពុំបានទទួលជំនួយផ្នែកច្បាប់ ពុំបានបន្តដំណើរការ**សំណុំរឿងរបស់ខ្លួនទៅតុលាការ**នោះទេ **ដោយសារខ្វះមធ្យោបាយផ្នែកហិរញ្ញវត្ថុ** (រដ្ឋប្បវេណី និង/ឬព្រហ្មទណ្ឌ)

៥. មានការទទួលស្គាល់ថា **រដ្ឋាភិបាលខ្វះហិរញ្ញប្បទាន**សម្រាប់ជំនួយផ្នែកច្បាប់ ដើម្បីឆ្លើយតបតាមតម្រូវការរបស់ប្រជាជន ជាពិសេសទៅកាន់ក្រុមងាយរងគ្រោះ ដូចជាសហគមន៍LGBTIQ បើទោះបីជាមានក្តីសង្ឃឹមកាន់តែច្រើននៅក្នុងកំណើនថវិកានាពេលបច្ចុប្បន្ន ព្រមទាំង**សេចក្តីព្រាងច្បាប់ថ្មីស្តីពីជំនួយផ្នែកច្បាប់ ដែលនឹងជួយបង្កើនលទ្ធភាពទទួលបានជំនួយផ្នែកច្បាប់ សម្រាប់អ្នកស្រលាញ់ភេទដូចគ្នា (LGBTIQ)** ក៏ដោយ

៦. **ការថយចុះម្ចាស់ជំនួយ** បានកម្រិតយ៉ាងខ្លាំងនូវសមត្ថភាពរបស់អង្គការសង្គមស៊ីវិល ក្នុងការផ្តល់ជំនួយផ្នែកច្បាប់ និងជំនួយពាក់ព័ន្ធដទៃទៀត ដែលមានគុណភាពខ្ពស់ សម្រាប់អ្នកស្រលាញ់ភេទដូចគ្នា (LGBTIQ) និងសហគមន៍ទូទៅ

៧. មាន**អវត្តមានស្ទើរតែទាំងស្រុងនៃវប្បធម៌ការបំពេញការងារស្ម័គ្រចិត្ត**ក្នុងចំណោមមេធាវីកម្ពុជា

៨. ការលើកចំណុចគួរជាទីសុទិដ្ឋិនិយមមួយ គឺ**ក្នុងចំណោមភាគីពាក់ព័ន្ធពាក់ទាំងអស់** រួមទាំង MoJ ផងដែរ មានឆន្ទៈដើម្បីកែលម្អលទ្ធភាពទទួលបានដំបូន្មានផ្នែកច្បាប់ និងជំនួយផ្នែកច្បាប់ ដោយសហគមន៍ LGBTIQ ក្នុងប្រទេសកម្ពុជា ជាពិសេស ក្នុង**ការផ្តល់ការបណ្តុះបណ្តាលដល់មេធាវី ដើម្បីបញ្ជ្រាបចំណេះដឹងអំពីបញ្ហាច្បាប់ពាក់ព័ន្ធជាមួយ SOGIESC។**

# បរិបទ

## ប្រព័ន្ធយុត្តិធម៌កម្ពុជា

ប្រព័ន្ធយុត្តិធម៌កម្ពុជា ផ្តល់ឱ្យមានប្រព័ន្ធតុលាការតាមបែបប្រពៃណី អមជាមួយនឹងយន្តការដោះស្រាយវិវាទក្រៅផ្លូវតុលាការ ដែលពឹងផ្អែកលើសន្ទានកម្ម។ ទោះជាយ៉ាងណាក្តី នៅក្រោមទិដ្ឋភាពផ្នែកច្បាប់នាពេលបច្ចុប្បន្ននេះ ជំនួយផ្នែកច្បាប់ឧបត្ថម្ភដោយរដ្ឋ គឺអាចផ្តល់ជូនបានសម្រាប់តែបទល្មើសព្រហ្មទណ្ឌពាក់ព័ន្ធជាមួយបទឧក្រិដ្ឋ និងបទមជ្ឈិមប៉ុណ្ណោះ។[9]

### ប្រព័ន្ធតុលាការ (សំណុំរឿងរដ្ឋប្បវេណី និងព្រហ្មទណ្ឌ)

ប្រព័ន្ធតុលាការកម្ពុជា បានទទួលមរតកពីប្រព័ន្ធច្បាប់ស៊ីវិល។ សម្រាប់សំណុំរឿងរដ្ឋប្បវេណី និងសំណុំរឿងព្រហ្មទណ្ឌ ប្រព័ន្ធច្បាប់ស៊ីវិល រួមមានដំណើរការបីថ្នាក់ ដោយចាប់ផ្តើមពីសាលាដំបូងរាជធានី និងខេត្ត បន្ទាប់មកឈានទៅដល់សាលាឧទ្ធរណ៍ ហើយតុលាកំពូល គឺជាតុលាការថ្នាក់ចុងក្រោយបំផុត។ ក្រុមប្រឹក្សាធម្មនុញ្ញអាចបើកសវនាការលើសំណួរស្តីពីទំនាស់/ ការបកស្រាយច្បាប់ ពាក់ព័ន្ធជាមួយរដ្ឋធម្មនុញ្ញ។




### យន្តការដោះស្រាយវិវាទដទៃទៀត

នៅអមជាមួយប្រព័ន្ធតុលាការដែលអាចត្រូវចំណាយអស់ថ្លៃខ្ពស់ យន្តការដោះស្រាយវិវាទតាមបែបប្រពៃណី នៅតែត្រូវបានប្រើប្រាស់នៅទូទាំងប្រទេស។ ជាការពិតណាស់ "ប្រសិនបើវិវាទនោះ ពុំសូវធ្ងន់ធ្ងរ ភាគីច្រើនតែដាក់វិវាទនោះទៅកាន់ចាស់ព្រឹទ្ធាចារ្យ ឬបុគ្គលដែលគេគោរព ឬបុគ្គលមានឥទ្ធិពលក្នុងភូមិ ឬឃុំរបស់ខ្លួន ដើម្បីផ្សះផ្សា"។[10] នេះគឺជាឧទាហរណ៍មួយអំពីគោលបំណងនៃ "មណ្ឌលសេវាយុត្តិធម៌" ទាំង ៦៦ កន្លែង ដំណើរការដោយក្រសួងយុត្តិធម៌នៅក្នុងទីរួមស្រុក ក្នុងខេត្តទាំង ១០ ដែលមន្ត្រីរដ្ឋាភិបាល ផ្តល់ដំបូន្មានផ្នែកច្បាប់ និងងាកទៅប្រើសន្ទានកម្មមុនពេលបញ្ជូនសំណុំរឿងទៅតុលាការ។[11] ស្រដៀងគ្នានេះដែរ បុគ្គលអាចប្រើប្រាស់មជ្ឈត្តិកម្ម ដោយ

---

[9] Annotated Cambodia Code of Procedure, Article 301, op. cit.

[10] Koy Neam, "Introduction to the Cambodian Judicial Process", The Asia Foundation, 1998, extracts available at http://www3.online.com.kh/users/kid/pdf/The%20Cambodian%20Judicial%20Process.pdf (18 February 2019).

[11] សម្គាល់៖ បច្ចុប្បន្ន ពុំមានការវាយតម្លៃឯករាជ្យលើប្រសិទ្ធផលនៃ "*ការិយាល័យយុត្តិធម៌*" ទាំងអស់នោះទេ ដោយមានភាពស្រពិចស្រពិលមួយចំនួនអំពីអ្នកពាក់ព័ន្ធខ្លះ ពេលនិយាយអំពីមុខងាររបស់ការិយាល័យនេះ។

ក្នុងនោះ ការសម្រេចរបស់មជ្ឈត្តិករ គឺមានអានុភាពចងកាតព្វកិច្ច ដូចគ្នាជាមួយនឹងសេចក្តីសម្រេចរបស់តុលាការដែរ។ ជាឧទាហរណ៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ទទួលបន្ទុករាល់បញ្ហាទាំងអស់ពាក់ព័ន្ធជាមួយនិយោជក និងនិយោជិត។ ជាចុងក្រោយប្រជាជនកម្ពុជា អាចដាក់ពាក្យបណ្តឹងវិវាទរដ្ឋប្បវេណី ទៅកាន់ព្រះមហាក្សត្រក្នុងអំឡុងពេលព្រះរាជសវនាការ ដែលដើរតួនាទីជាវេទិកាយុត្តិធម៌បន្ថែម។[12]

## បញ្ហាផ្នែកច្បាប់ពាក់ព័ន្ធជាមួយ SOGIESC ដែលច្រើនកើតមានបំផុតក្នុងប្រទេសកម្ពុជា

នៅក្នុងការស្ទាបស្ទង់មតិទូទាំងប្រទេសមួយ ធ្វើឡើងដោយសហគមន៍ឥន្ទធនូកម្ពុជា (RoCK) ក្នុងឆ្នាំ ២០១៥ បានឱ្យដឹងថា ៨៦% នៃអ្នកផ្តល់ចម្លើយជាអ្នកស្រលាញ់ភេទផ្ទុយគ្នា និង ៨២% នៃអ្នកផ្តល់ចម្លើយជាអ្នកស្រលាញ់ភេទដូចគ្នា(LGBTIQ) បានកំណត់ឃើញថា បញ្ហាទីមួយដែលសហគមន៍LGBTIQ ក្នុងប្រទេសកម្ពុជាជួបប្រទះ គឺរងការរើសអើងផ្អែកលើ SOGIE។ មិនថារដ្ឋធម្មនុញ្ញ ឬច្បាប់ក្តី ពុំបានការពារ LGBTIQ ពីការរើសអើងឡើយ។ ទោះយ៉ាងណាក្តី មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ធានាសិទ្ធិស្មើភាពគ្នាសម្រាប់ប្រជាជនកម្ពុជាគ្រប់រូប "ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។"[13] គេអាចអះអាងបានថា យោងតាមការបកស្រាយតាមរយៈយន្តការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ឬតុលាការសិទ្ធិមនុស្សថ្នាក់តំបន់ និន្នាការភេទ និង/ឬ អត្តសញ្ញាណយេនឌ័រ និងការការបង្ហាញនូវទំនោរយេនឌ័រ អាចស្ថិតនៅក្នុងទីតាំង "ស្ថានភាពដទៃទៀត" ហេតុនេះហើយអ្នកស្រលាញ់ភេទដូចគ្នា (LGBTIQ)ក្នុងប្រទេសកម្ពុជា អាចមានសិទ្ធិទទួលបានការការពារពីរដ្ឋធម្មនុញ្ញ។[14] ទោះយ៉ាងណាក្តី ការបកស្រាយបែបនេះ នៅពុំទាន់ត្រូវបានធ្វើឡើងដោយក្រុមប្រឹក្សាធម្មនុញ្ញ ឬតុលាការកម្ពុជានៅឡើយ។

ក្រៅពីការរើសអើង បញ្ហា SOGIESC សំខាន់ៗបំផុតក្នុងប្រទេសកម្ពុជា គឺពាក់ព័ន្ធជាមួយទំនាក់ទំនងគ្រួសារ ដោយរួមមានដូចជា អំពើហិង្សាផ្នែករាងកាយ និងអំពើហិង្សាផ្លូវចិត្ត ប្រព្រឹត្តដោយសមាជិកគ្រួសារខ្លួនមកលើអ្នកស្រលាញ់ភេទដូចគ្នា(LGBTIQ) ការធ្វើបាបនៅសាលារៀន និងកន្លែងធ្វើការ និងការបៀតបៀនមកលើ LGBTIQ (ពួកគាត់មួយចំនួនជាអ្នករកស៊ីផ្លូវភេទផងដែរ) ពីសំណាក់អាជ្ញាធរ។ កម្រងច្បាប់ចំនួនបី ត្រូវបានកំណត់

---

[12] Koy Neam, "Introduction to the Cambodian Judicial Process", The Asia foundation, 1998, op. cit.

[13] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រា ៣១ ថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ ១៩៩៣ អាចបើកមើលបាននៅ http://pressocm.gov.kh/en/archives/9539 (បើកមើលចុងក្រោយនៅថ្ងៃទី ២៣ ខែមករា ឆ្នាំ ២០១៩)។

[14] សូមមើលជាឧទាហរណ៍៖ International Commission of Jurists, SOGI Casebook, 2018 អាចបើកមើលបាននៅ https://www.icj.org/sogi-casebook-introduction/ (បើកមើលចុងក្រោយនៅថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ២០១៩)។

ឃើញថា ត្រូវបានយកមកប្រើប្រាស់ជាប្រចាំ ដើម្បីបំបែកដៃគូ LGBTIQ ពោលគឺ៖ ច្បាប់ប្រឆាំងការចាប់ជំរិត ច្បាប់ប្រឆាំងការជួញដូរ និងគោលនយោបាយភូមិឃុំសុវត្ថិភាព។[15]

ការស្ទាបស្ទង់មតិធ្វើឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) ក្នុងឆ្នាំ ២០១៥ បង្ហាញឱ្យឃើញថា "៩៣,៥៩% នៃអ្នកចូលរួម ដែលធ្លាប់ត្រូវបានគេធ្វើបាប មានអារម្មណ៍ថា ការធ្វើបាបបណ្តាលមួយផ្នែក ឬទាំងស្រុងមកពីនិន្នាការផ្លូវភេទ ឬអត្តសញ្ញាណយេនឌ័ររបស់ពួកគេ។"[16] បន្ថែមលើនេះ ៩២% នៃស្ត្រីអ្នកប្តូរភេទនៅក្នុងការស្ទាបស្ទង់មតិរបស់ CCHR ក្នុងឆ្នាំ២០១៦ បានរាយការណ៍ថា ធ្លាប់ជួបបទពិសោធន៍រងការរំលោភបំពានតាមពាក្យសម្តីក្នុងទីសាធារណៈ ដោយសារតែ SOGIESC របស់ខ្លួន ចំណែក ៤៣% ទៀត បានរាយការណ៍ថា ធ្លាប់ជួបបទពិសោធន៍អំពើហិង្សាផ្លូវកាយ និង ៣១% ធ្លាប់ជួបបទពិសោធន៍ការធ្វើបាបផ្លូវភេទ។[17] ជាលទ្ធផល មានការប៉ាន់ប្រមាណថា ជិតមួយភាគបីនៃ LGBTកម្ពុជា ពុំធ្លាប់បានហ៊ានបង្ហាញខ្លួន ដោយបង្ខំចិត្តបដិសេធលក្ខណៈជាខ្លួនឯង ព្រោះតែភ័យខ្លាចការនិរទេសផ្នែកសង្គម។[18]

---

[15] "Being LGBT in Asia: Cambodia Country Report", United Nations Development Programme and United States Agency for International Development, 2014, p. 36, op. cit.

[16] Cambodian Center for Human Rights, "LGBT Bullying in Cambodia's schools", December 2015, p. 16, អាចបើកមើលបាននៅ https://cchrcambodia.org/admin/media/report/report/english/2015_12_17_CCHR_REPORT_LGBT_Bullying_in_Cam_School_(ENG).pdf (បើកមើលចុងក្រោយនៅថ្ងៃទី ២៤ ខែមករា ឆ្នាំ ២០១៩)។

[17] Cambodian Center for Human Rights, "Discrimination against Transgender Women in Cambodia's Urban centers, September 2016, p-10-12, អាចបើកមើលបាននៅ https://cchrcambodia.org/admin/media/report/report/english/2016_09_21_SOGI_Report_Eng.pdf (បើកមើលចុងក្រោយនៅថ្ងៃទី ២៤ ខែមករា ឆ្នាំ ២០១៩)។

[18] Rainbow Community of Kampuchea, Research Report on Opinions, Attitudes and Behavior toward the LGBT population in Cambodia, December 2015, p. 9.

## លទ្ធភាពទទួលបានជំនួយផ្នែកច្បាប់សម្រាប់សហគមន៍ LGBTIQ ក្នុងប្រទេសកម្ពុជា

ក្នុងផ្នែកខាងក្រោមនេះ យើងបានវិភាគលើទិន្នន័យប្រមូលបានក្នុងអំឡុងពេលស្ទាបស្ទង់មតិ និងបានបកស្រាយដោយឆ្លុះបញ្ចាំងទៅលើព័ត៌មានប្រមូលបានក្នុងអំឡុងពេលសម្ភាសន៍ និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ។ ក្រុមអ្នកផ្តល់ចម្លើយរបស់យើងមានលក្ខណសម្បត្តិដូចខាងក្រោម ដែលអនុលោមតាមលក្ខណៈប្រជាសាស្រ្តនៃប្រជាជនកម្ពុជា ទាក់ទងទៅនឹងក្រុមអាយុ។[19]

| លក្ខណសម្បត្តិផ្នែកប្រជាសាស្រ្ត | | % នៃអ្នកចូលរួម |
|---|---|---|
| ក្រុមអាយុ | ក្រោម ៣៥ ឆ្នាំ | ៦៨,៧៥% |
| | ៣៥ ឆ្នាំឡើងទៅ | ២៩,១៧% |
| | ពុំមានការផ្តល់ចម្លើយ | ២,០៨% |
| ទីតាំង | ភ្នំពេញ | ៣៩,៥៨% |
| | តាមបណ្តាខេត្ត | ៦០,៤២% |
| អត្តសញ្ញាណយេនឌ័រ | ស្រី | ៣៧,៥០% |
| | ប្រុស | ២៩,១៧% |
| | មិនកំណត់ភេទ | ១,០៤% |
| | ស្រ្តីប្តូរភេទ (TGW) | ៦,២៥% |
| | បុរសប្តូរភេទ (TGM) | ២០,៨៣% |
| | ពុំមានការផ្តល់ចម្លើយ | ៣,១៣% |
| | មិនចង់និយាយ | ២,០៨% |
| និន្នាការភេទ | ស្រលាញ់ទាំងពីរភេទ | ៨,៣៣% |
| | ស្រលាញ់ភេទផ្ទុយគ្នា | ៧,២៩% |
| | ប្រុសស្រលាញ់ភេទដូចគ្នា | ២៥,០០% |
| | ស្រីស្រលាញ់ភេទដូចគ្នា | ៥៧,២៩% |
| | មិនចង់និយាយ | ២,០៨% |

## ភស្តុតាងការទទួលបានមេធាវី

បីភាគបួននៃអ្នកផ្តល់ចម្លើយបានរាយការណ៍ថា ពួកគេពុំធ្លាប់ត្រូវការមេធាវីទេ។ ក្នុងចំណោមអ្នកផ្តល់ចម្លើយដែលឆ្លើយតបវិជ្ជមាន ភាគច្រើនគឺរស់នៅតាមខេត្ត (៥៧,៨៩%) ហើយភាគច្រើន គឺជាស្រ្តីស្រលាញ់ភេទដូចគ្នា (៨៤,២១%) ដោយក្នុងនោះ ៤៣,៧៥% បានកំណត់អត្តសញ្ញាណខ្លួនឯងថា ជាអ្នកប្តូរភេទបុរស។[20] លទ្ធផល

[19] សម្គាល់៖ វិទ្យាស្ថានជាតិស្ថិតិកម្ពុជា បញ្ជាក់ថា ៦៨,៥ ភាគរយនៃប្រជាជនស្ថិតក្រោមអាយុ ៣៥ ឆ្នាំក្នុងឆ្នាំ ២០១៣។ សូមមើល https://www.cambodiadaily.com/news/baby-boom-after-khmer-rouge-led-to-cambodias-young-population-127415/ (បើកមើលចុងក្រោយនៅថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០១៩)។

[20] សម្គាល់៖ ក្នុងប្រទេសកម្ពុជា ជារឿងធម្មតាចំពោះបុគ្គលដែលកំណត់អត្តសញ្ញាណខ្លួនឯងថា ជាអ្នកប្តូរភេទបុរស ក្នុងការកំណត់អត្តសញ្ញាណខ្លួនឯងថាជាស្រ្តីស្រលាញ់ភេទដូចគ្នា បើទោះបីជាគេអាចសន្មតថា អ្នកប្តូរភេទបុរសមានការរួមភេទជាមួយស្រ្តី អាចកំណត់ខ្លួនឯង

ទាំងអស់នោះ ស្វែងរកការពន្យល់លើចំណុចដែលអ្នកផ្តល់ចម្លើយរស់នៅក្នុងក្រុងភ្នំពេញ អាចជួបប្រទះបញ្ហាខុសប្លែកពីអ្នករស់នៅក្នុងតំបន់ជនបទ ជាហេតុធ្វើឱ្យពួកគេ ពុំត្រូវការប្រើប្រាស់មេធាវី។ បន្ថែមលើនេះទៀត ដោយសារនៅក្រុងភ្នំពេញមានអង្គការក្រៅរដ្ឋាភិបាលជាច្រើនធ្វើការលើការផ្តល់ជំនួយផ្នែកច្បាប់ ដែលចំណុចនេះអាចចូលរួមចំណែកធ្វើឱ្យចំនួនអ្នកតាំងលំនៅក្នុងក្រុងភ្នំពេញដែលទៅរកមេធាវីបានថយចុះ បូករួមជាមួយទស្សនៈយល់ឃើញថាអង្គការក្រៅរដ្ឋាភិបាលដែលផ្តល់ជំនួយផ្នែកច្បាប់ ពុំមែនជាមេធាវីទេ។

នៅពេលមានការសួរទៅអ្នកផ្តល់ចម្លើយ ថាតើត្រូវទៅរកមេធាវីនៅឯណា ប្រសិនបើគេត្រូវការមេធាវីនោះ ចម្លើយ[21] គឺមានភាពចម្រុះគ្នាយ៉ាងខ្លាំង ដោយមានភាពខុសគ្នាគួរជាទីកត់សម្គាល់ផ្អែកលើទីតាំង។ ជាការពិតណាស់ អ្នកផ្តល់ចម្លើយដែលរស់នៅក្នុងក្រុងភ្នំពេញ មានលទ្ធភាពក្នុងការចូលទៅរកអង្គការសង្គមស៊ីវិល ដែលគេស្គាល់ថា ជាអ្នកផ្តល់ជំនួយផ្នែកច្បាប់ច្រើនជាង បើទោះបីជាអង្គការសង្គមស៊ីវិលទាំងនោះមួយចំនួន មានការិយាល័យនៅតាមខេត្តដែរក្តី ទៅរកមេធាវីឯកជន និងទៅរកក្រសួងយុត្តិធម៌។ ទោះយ៉ាងណាក្តី អ្នកផ្តល់ចម្លើយនៅតាមខេត្ត មានភាពងាយស្រួលក្នុងការទំនាក់ទំនងមក RoCK ឬនគរបាល។ ជាលទ្ធផល ហាក់មានភាពងាយស្រួលក្នុងការចូលទៅរកជំនួយផ្នែកច្បាប់ មិនថាជាជំនួយផ្នែកច្បាប់ឯកជន ឬសាធារណៈក្តី ក្នុងក្រុងភ្នំពេញច្រើនជាងតាមខេត្ត ជាហេតុធ្វើឱ្យថ្មីៗនេះ MoJ បានធ្វើការសម្រេចចិត្តដាក់ពង្រាយមេធាវីបួនទៅប្រាំនាក់ តាមបណ្តាខេត្តនីមួយៗរបស់ប្រទេសកម្ពុជា។ បច្ចុប្បន្ន ពុំមានការសិក្សាពិនិត្យគ្រប់គ្រាន់ ដើម្បីវិភាគលើផលនៃវិធានការនេះទេ។

---

ជាមនុស្សស្រលាញ់ភេទដូចគ្នាក្តី។ ពុំមានការសិក្សាផ្នែកសង្គមវិទ្យា ត្រូវបានធ្វើឡើងស្តីពីដំណើរការនៃការកំណត់អត្តសញ្ញាណខ្លួនឯង និងអត្ថន័យផ្នែកវប្បធម៌របស់សហគមន៍ LGBTIQ ក្នុងប្រទេសកម្ពុជាឡើយ។ ហេតុដូច្នេះ ក្នុងរបាយការណ៍នេះ យើងបានជ្រើសរើសគោរពតាមការកំណត់អត្តសញ្ញាណដោយខ្លួនឯងរបស់អ្នកផ្តល់ចម្លើយ បើទោះបីជាការធ្វើបែបនេះ អាចបង្កការភាន់ច្រលំមួយចំនួនសម្រាប់អ្នកអានក្តី។

[21] សម្គាល់៖ អ្នកផ្តល់ចម្លើយ អាចដាក់ចម្លើយជាច្រើន ហេតុនេះ អ្នកផ្តល់ចម្លើយ ២៤ នាក់ បានផ្តល់ចម្លើយចំនួន ៣១។

| អង្គការ | ចំនួនអ្នកផ្តល់ចម្លើយ | % | *ភ្នំពេញ* | % សរុបនៃអ្នករស់នៅក្នុងក្រុងភ្នំពេញ | *ខេត្ត* | % សរុបនៃអ្នករស់នៅតាមខេត្ត |
|---|---|---|---|---|---|---|
| CCHR | ៥ | ២០,៨៣% | ៤ | ៨០,០០% | ០ | ០,០០% |
| ក្រសួងយុត្តិធម៌ | ៣ | ១២,៥០% | ២ | ៦៦,៦៧% | ១ | ៣៣,៣៣% |
| ការិយាល័យមេធាវីឯកជន | ៥ | ២០,៨៣% | ៤ | ៨០,០០% | ០ | ០,០០% |
| អាដហុក | ៣ | ១២,៥០% | ១ | ៣៣,៣៣% | ១ | ៣៣,៣៣% |
| លីកាដូ | ៣ | ១២,៥០% | ២ | ៦៦,៦៧% | ០ | ០,០០% |
| RoCK | ៧ | ២៩,១៧% | ០ | ០,០០% | ៦ | ៨៥,៧១% |
| គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (BAKC) | ១ | ៤,១៧% | ១ | ១០០,០០% | ០ | ០,០០% |
| អង្គការជំនួយផ្នែកច្បាប់កម្ពុជា (LAC) | ១ | ៤,១៧% | ១ | ១០០,០០% | ០ | ០,០០% |
| មិនពាក់ព័ន្ធ | ១ | ៤,១៧% | ០ | ០,០០% | ១ | ១០០,០០% |
| នគរបាល | ២ | ៨,៣៣% | ០ | ០,០០% | ២ | ១០០,០០% |
| អង្គការស្ថានយុត្តិធម៌អន្តរជាតិ (IBJ) | ០ | ០,០០% | ០ | ០,០០% | ០ | ០,០០% |
| ផ្សេងទៀត | ០ | ០,០០% | ០ | ០,០០% | ០ | ០,០០% |
| សរុបចម្លើយ | ៣១ | | ១៥ | | ១១ | |
| មិនមានទីតាំង៖ អ្នកផ្តល់ចម្លើយ ៥ នាក់ | | | ៤៨,៣៩% | | ៣៥,៤៨% | |

ក្នុងចំណោមអ្នកផ្តល់ចម្លើយ ២៥% ដែលទទួលស្គាល់ថា ធ្លាប់ត្រូវការមេធាវី ៦៦,៦៧% បានបញ្ជាក់ SOGIESC របស់ខ្លួនប្រាប់ទៅមេធាវី ៦២,៥០% បានបញ្ជាក់ថា មិនពាក់ព័ន្ធជាមួយសំណុំរឿងរបស់ពួកគេ និង ២៥% បញ្ជាក់ថា មានការភ័យខ្លាចត្រូវរងការរើសអើសពីមេធាវីរបស់ខ្លួន។ ទោះយ៉ាងណាក្តី ក្នុងចំណោមអ្នកផ្តល់ចម្លើយ ដែលបានបញ្ជាក់ SOGIESC របស់ខ្លួន ភាគច្រើនពួកគេប្រាប់ទៅកាន់អង្គការក្រៅរដ្ឋាភិបាល ឬមេធាវីឯកជនដែលជួលដោយអង្គការក្រៅរដ្ឋាភិបាល។ ការស្រាវជ្រាវរបស់យើង ពុំបានកំណត់ច្បាស់លាស់ថា តើ ២៥% ដែលបានបញ្ជាក់ថា ភ័យខ្លាចការរើសអើងនោះ គឺជាប់ទាក់ទងជាមួយមេធាវីដែលផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាលឬ យ៉ាងណានោះទេ។

នៅពេលត្រូវបានសួរជាក់លាក់អំពីមេធាវីដែលផ្តល់ជំនួយផ្នែកច្បាប់ដល់បុគ្គល LGBTIQ បុគ្គលចំនួន ២៥ នាក់[22] បានកំណត់អំពីស្ថាប័នខាងក្រោមនេះ ថាជាអ្នកផ្តល់មេធាវីជំនួយផ្នែកច្បាប់៖ RoCK ចំនួន ៦៨%, អាដហុក ចំនួន ២៤%, CCHR ចំនួន ២៤%, លីកាដូចំនួន ១៦%, LAC ចំនួន ៨%, IBJ ចំនួន ៤%, MoJ ចំនួន ៤%, និង OHCHR កម្ពុជាចំនួន ៤%។ ទោះយ៉ាងណាក្តី ចម្លើយទាំងនោះ ពុំឆ្លុះបញ្ចាំងទាំងស្រុងអំពីព័ត៌មានដែលប្រមូលបានតាមរយៈការសម្ភាសន៍នោះទេ ដោយហេតុថា អ្នកពាក់ព័ន្ធភាគច្រើន បញ្ជូនសំណុំរឿងរបស់ខ្លួនដែលពាក់ព័ន្ធជាមួយបញ្ហា SOGIESC មកកាន់ CCHR ។ ជាការសំខាន់ដែលគួរកត់សម្គាល់ថា អង្គការនីមួយៗដូចបានបញ្ជាក់

[22] សម្គាល់៖ អ្នកផ្តល់ចម្លើយ អាចដាក់ចម្លើយជាច្រើន ហេតុនេះ អ្នកផ្តល់ចម្លើយ ២៥ នាក់ បានផ្តល់ចម្លើយចំនួន ៤០។

ខាងលើ យកលក្ខខណ្ឌវិនិច្ឆ័យផ្សេងៗគ្នាមកអនុវត្តផ្អែកលើបញ្ហាតាមវិស័យ គុណភាពនៃសំណុំរឿង និងការពិនិត្យឡើងវិញដោយគណៈកម្មាធិការផ្ទៃក្នុង។ ចំណុចនេះ ចូលរួមចំណែកធ្វើឱ្យមានកង្វះភាពច្បាស់លាស់ ស្តីពីយន្តការបញ្ជូនដែលមានលក្ខណៈឯកភាពគ្នាពាក់ព័ន្ធជាមួយបញ្ហា SOGIESC (សូមមើលសំណុំរឿងរបស់ ផ្លុង ស្រីរ៉ាន់ ជាឧទាហរណ៍)។

**ឧទាហរណ៍អំពីសំណុំរឿង LGBTIQ ដែលត្រូវរត់ចុះរត់ឡើង ស្វែងរកជំនួយផ្នែកច្បាប់**

ក្នុងខែសីហា ឆ្នាំ ២០១១ ផ្លុង ស្រីរ៉ាន់ ដែលជាបុរសប្តូរភេទទៅជាស្ត្រី ត្រូវបានចាប់ខ្លួនបន្ទាប់ពីរងការចោទប្រកាន់ពីបងប្រុសរបស់មិត្តស្រីនាង ស្តីពីការឃុំខ្លួនខុសច្បាប់ និងការជួញដូរមនុស្ស។ ក្នុងខែវិច្ឆិកា ឆ្នាំ ២០១១ នាងត្រូវបានតុលាការបានដាក់ទោសបទព្រហ្មទណ្ឌពីបទ រួមភេទជាមួយអនីតិជន (មិត្តស្រីរបស់នាង) ហើយត្រូវផ្តន្ទាទោសជាប់ពន្ធនាគាររយៈពេលប្រាំឆ្នាំ។ ទោះយ៉ាងណាក្តី នាងអះអាងថា ឯកសារដែលគ្រួសារបានផ្តល់ឱ្យដែលអះអាងថា ក្មេងស្រីនោះមានអាយុតែ ១៤ ឆ្នាំ គឺជាឯកសារក្លែងក្លាយ ហើយឯកសារនោះគ្រាន់តែមានបំណង ដើម្បីបញ្ចប់ទំនាក់ទំនងភេទដូចគ្នារបស់កូនស្រីពួកគេប៉ុណ្ណោះ។ នាងចង់ដាក់បណ្តឹងឧទ្ធរណ៍។

ម្តាយរបស់នាងបានទំនាក់ទំនងមកមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ប៉ុន្តែអង្គការនេះ ពុំមានសេវាផ្នែកច្បាប់ ហេតុនេះក៏បានបញ្ជូនម្តាយរបស់ស្រីរ៉ាន់ ទៅកាន់អង្គការសង្គមស៊ីវិលមួយទៀត ដែលមានឯកទេសលើជំនួយផ្នែកច្បាប់ ដែលពុំអាចជួយបានដែរ។ ក្រោយពីបានព្យាយាមទទួលព័ត៌មានពីអង្គការខាងក្រោយនេះ សហគមន៍ឥន្ទធនូកម្ពុជា បានទំនាក់ទំនងទៅកាន់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា(OHCHR-Cambodia)ដែលបានយល់ព្រមជួយក្នុងសំណុំរឿងនេះ។ ស្របពេលជាមួយគ្នានោះដែរ ករណីត្រូវបានបញ្ជូនទៅកាន់អង្គការជំនួយផ្នែកច្បាប់កម្ពុជា ប៉ុន្តែមេធាវីទទួលបន្ទុក កំពុងស្ថិតក្នុងពេលឈប់សម្រាកលំហែមាតុភាព ហើយពុំមាននរណាម្នាក់មកទទួលភារកិច្ចជំនួសនាងឡើយ។ ហេតុដូច្នេះ OHCHR-កម្ពុជា បានជួលមេធាវីថ្មី តាងនាមឱ្យស្រីរ៉ាន់ ដែលគួរឱ្យសោកស្តាយ ហាក់មិនសូវចាប់អារម្មណ៍ក្នុងការស្វែងរកយុត្តិធម៌សម្រាប់បុគ្គល LGBTIQ ទេ ប៉ុន្តែខ្វល់តែរឿងប្រាក់ប៉ុណ្ណោះ។ ហេតុដូច្នេះ នៅទីបំផុត ROCK បានជួលមេធាវីម្នាក់ទៀតមកពីអង្គការលីកាដូ ដើម្បីបន្តការពារសំណុំរឿងនេះ។

នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១២ សាលាឧទ្ធរណ៍បានច្រានចោលដីកាសម្រេចឱ្យមានទោសក្នុងឆ្នាំ ២០១១ នៃសាលាដំបូងរាជធានីភ្នំពេញ ដោយផ្អែកលើកង្វះភស្តុតាង ដើម្បីបង្ហាញថាក្មេងស្រីនោះជាអនីតិជន។

## ការយល់ដឹងអំពីជំនួយផ្នែកច្បាប់របស់សហគមន៍ LGBTIQ

នៅពេលផ្តល់និយមន័យមូលដ្ឋានជំនួយផ្នែកច្បាប់ថាជា "ការបង់ប្រាក់ដោយប្រើហិរញ្ញប្បទានសាធារណៈ ដើម្បីជួយទូទាត់សម្រាប់ដំបូន្មានផ្នែកច្បាប់ ឬនីតិវិធីផ្នែកច្បាប់សម្រាប់អ្នកដែលត្រូវការមេធាវី ហើយពុំអាចមានលទ្ធភាពបង់ថ្លៃមេធាវីបាន" ៣៤,៣៨% នៃអ្នកផ្តល់ចម្លើយទាំងអស់ ពុំយល់អំពីទស្សនាទានស្តីពីជំនួយផ្នែកច្បាប់ទេ បើ

ធៀបជាមួយចំនួន ៣៨,៥៤% ដែលបានរាយការណ៍ថា ខ្លួនយល់អំពីនិយមន័យនេះ។ លទ្ធផលនេះ ត្រូវបានជំរុញបន្ថែមដោយ ៥៣,១៣% នៃអ្នកផ្តល់ចម្លើយទាំងអស់តបថា ខ្លួនពុំដែលបានទទួលព័ត៌មានណាមួយអំពីជំនួយផ្នែកច្បាប់នោះឡើយ ដោយក្នុងនោះមានតែ ៥,២៥% ប៉ុណ្ណោះ ដែលបានរាយការណ៍ថា បានទទួលព័ត៌មានជាប្រចាំស្តីពីជំនួយផ្នែកច្បាប់។

ជាលទ្ធផល ៦២,៥០% នៃអ្នកផ្តល់ចម្លើយទាំងអស់គិតថា ពួកគេពុំមានលក្ខណសម្បត្តិអាចទទួលបានជំនួយផ្នែកច្បាប់ឡើយ បើទោះបីជាពុំមានលក្ខខណ្ឌវិនិច្ឆ័យណាមួយត្រូវបានផ្តល់ជូនដល់អ្នកផ្តល់ចម្លើយ ក្រៅពីនិយមន័យដ៏ទូលាយដូចបានបញ្ជាក់ខាងលើ។ នៅពេលអវត្តមានច្បាប់ស្តីពីជំនួយផ្នែកច្បាប់ ពុំមានលក្ខខណ្ឌវិនិច្ឆ័យច្បាស់លាស់ និងអាចវាស់វែងបានត្រូវបានដាក់ចេញសម្រាប់ជំនួយផ្នែកច្បាប់ឧបត្ថម្ភដោយរដ្ឋ ក្រៅពីលក្ខខណ្ឌវិនិច្ឆ័យអំពី "ភាពក្រីក្រ" ដែលអាចមានលក្ខណៈធៀប ឬជាបញ្ហាពាក់ព័ន្ធជាមួយទស្សនៈយល់ឃើញប៉ុណ្ណោះ។

នៅក្នុងការប្រមូលទិន្នន័យរបស់យើងទាំងមូល យើងបានរកឃើញភាពមិនស៊ីសង្វាក់គ្នានៅក្នុងចម្លើយរបស់អ្នកផ្តល់ចម្លើយអាស្រ័យដោយកង្វះការយល់ដឹងអំពីជំនួយផ្នែកច្បាប់។ បន្ថែមលើនេះ សម្រាប់អ្នកផ្តល់ចម្លើយមួយចំនួនរបស់យើង មេធាវីធ្វើការឱ្យអង្គការក្រៅរដ្ឋាភិបាល ដែលអាចផ្តល់ការជួយជ្រោមជ្រែងផ្នែកច្បាប់ដោយឥតគិតថ្លៃ ពុំត្រូវបានមើលឃើញថាជាមេធាវី "ពិតប្រាកដ" ឡើយ។ ចំណុចនេះ អាចពន្យល់អំពីមូលហេតុដែលធ្វើឱ្យថ្វីបើមានតែអ្នកផ្តល់ចម្លើយតែ ២៥% ប៉ុណ្ណោះ ដែលបានបញ្ជាក់ថាធ្លាប់ត្រូវការមេធាវីនៅពេលចាប់ផ្តើមដំបូងនៃការស្ទាបស្ទង់មតិរបស់យើង អ្នកផ្តល់ចម្លើយក្នុងចំនួនដ៏ខ្ពស់ជាងនេះពោលគឺ ២៨,១៣% បែរជាបញ្ជាក់ថាធ្លាប់បានដាក់ពាក្យសុំជំនួយផ្នែកច្បាប់នៅពេលកន្លងមក។ ឥរិយាបថនេះ ត្រូវបានបញ្ជាក់អះអាងដោយអង្គការសង្គមស៊ីវិលពាក់ព័ន្ធ ដោយពួកគាត់មួយចំនួនបានបន្ថែមថា ពុំមែនគ្រប់ករណីទាំងអស់ ត្រូវការជំនួយមេធាវីការពារក្តីនោះទេ ពោលគឺត្រឹមដំបូន្មានពីអ្នកប្រកបវិជ្ជាជីវៈអមអាជីព ឬការធ្វើសន្ទានកម្មរវាងភាគី គឺគ្រប់គ្រាន់ហើយ។

## កម្រិតនៃទំនុកចិត្តរបស់អ្នកស្រលាញ់ភេទដូចគ្នា(LGBTIQ) នៅលើយន្តការជំនួយផ្នែកច្បាប់

នៅពេលសួរថា តើពួកគេទុកចិត្តមេធាវីដែលផ្តល់ជំនួយផ្នែកច្បាប់ឬទេ ៤៧,៩២% នៃអ្នកស្រលាញ់ភេទដូចគ្នា(LGBTIQ)ដែលបានឆ្លើយតបបានរាយការណ៍ថា ពួកគេពិតជាមិនទុកចិត្តមេធាវីទេ ដោយក្នុងនោះមានតែ ១០,៤២% ប៉ុណ្ណោះដែលជឿទុកចិត្ត។ ហេតុផលសម្រាប់ចំណុចនេះ គឺដោយសារមានការសន្មតជាទូទៅថា មេធាវីដែលធ្វើការដោយ



ឥតគិតថ្លៃ (ឬបានទទួលប្រាក់កម្រៃតិចតួច) ពុំមែនជាមេធាវីពូកែឡើយ។ បន្ថែមលើនេះ មានការសង្កេតឃើញពីសំណាក់អ្នកពាក់ព័ន្ធជាច្រើនថា មានភាពខុសប្លែកគ្នាគួរជាទីកត់សម្គាល់ចំពោះគុណភាពនៃជំនួយផ្នែកច្បាប់ផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាល និងសេវាផ្តល់ដោយមេធាវីរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដោយក្នុងនោះសេវាជំនួយផ្នែកច្បាប់របស់អង្គការក្រៅរដ្ឋាភិបាល ត្រូវបានទទួលស្គាល់ថាមានភាពសព្វជ្រុងជ្រោយ និងមានប្រសិទ្ធភាពលើបញ្ហាតាមវិស័យច្រើនជាង ដែលអាចចូលរួមចំណែកធ្វើឱ្យមានទស្សនៈយល់ឃើញដូចខាងលើ។

អង្គការសង្គមស៊ីវិលយ៉ាងតិចចំនួនពីរ បានបញ្ជាក់អំពីគម្រោងកាលពីកន្លងមក ក្នុងការផ្តល់ជំនួយផ្នែកច្បាប់លើបញ្ហាពាក់ព័ន្ធជាមួយនឹងSOGIESC ដែលត្រូវបានបញ្ឈប់នាពេលថ្មីៗនេះ ដោយបានបញ្ជាក់ថាមេធាវីរបស់ពួកគេបានទទួលការបណ្តុះបណ្តាលជាច្រើន ដើម្បីសិក្សាអំពីរបៀបធ្វើការទៅលើបញ្ហាជាក់លាក់ទាំងនោះ។ ជាការពិតណាស់ ថ្វីបើសិស្សមេធាវី និងសិស្សចៅក្រមទទួលបានការបណ្តុះបណ្តាលស្តីពីបញ្ហាសិទ្ធិមនុស្សក្តី ប៉ុន្តែសិស្សទាំងនេះបច្ចុប្បន្ន ពុំបានទទួលការបណ្តុះបណ្តាលស្តីពីបញ្ហា SOGIESC/LGBTIQ នោះទេ។ ប៉ុន្តែក្រសួងយុត្តិធម៌បានបញ្ជាក់អំពីភាពបើកទូលាយរបស់ខ្លួនក្នុងការសហការផ្តល់វគ្គបណ្តុះបណ្តាលលើមូលដ្ឋានចំពោះកិច្ច ជាមួយដៃគូអង្គការសហប្រជាជាតិ និង/ឬ អង្គការសង្គមស៊ីវិល។

## បទពិសោធន៍របស់អ្នកស្រលាញ់ភេទដូចគ្នា(LGBTIQ) ក្នុងការទៅរកជំនួយផ្នែកច្បាប់

ក្នុងចំណោមអ្នកផ្តល់ចម្លើយរបស់យើង ២៨,១៣% បានរាយការណ៍ថា ធ្លាប់បានដាក់ពាក្យសុំជំនួយផ្នែកច្បាប់រួចមកហើយ ដោយក្នុងចំណោមអ្នកទាំងនោះ ៧៥% បានរាយការណ៍ថា ការស្នើសុំនោះមានជាប់ពាក់ព័ន្ធជាមួយនឹងសកម្មភាពរើសអើងផ្អែកលើ SOGIESC របស់ពួកគេ។

៦២,៨៦% នៃអ្នកដែលបានដាក់ពាក្យសុំជំនួយផ្នែកច្បាប់សាធារណៈ ប៉ុន្តែពុំបានទទួលជំនួយនេះ បានបញ្ជាក់ថា ពួកគេនៅតែស្វែងរកប្រាក់ដើម្បីអាចបង់ថ្លៃមេធាវីរបស់ខ្លួន ចំណែកអ្នកផ្តល់ចម្លើយភាគច្រើនបានបញ្ជាក់ថាពួកគេបានបោះបង់សំណុំរឿង ដោយសារកង្វះមធ្យោបាយផ្នែកហិរញ្ញវត្ថុ។ ក្នុងចំណោមអ្នកផ្តល់ចម្លើយ ៣៧,១៤% ដែលពុំបានទទួលជំនួយផ្នែកច្បាប់សាធារណៈ ប៉ុន្តែមានលទ្ធភាពអាចដំណើរការរឿងក្តីរបស់ខ្លួន ដោយ ២០% បានទទួលជំនួយតាមរយៈអង្គការក្រៅរដ្ឋាភិបាល និង ៥,៧១% បញ្ជាក់ថាមេធាវីទទួលយកសំណុំរឿងដោយឥតគិតថ្លៃ។ ថ្វីបើពុំមានទិន្នន័យប្រហាក់ប្រហែលនេះកន្លងមកដើម្បីអាចទាញការប្រៀបធៀបគ្នាក្តី ប៉ុន្តែដោយសារមេធាវីរបស់អង្គការសង្គមស៊ីវិលត្រូវបានកាត់បន្ថយចំនួន ៥៣% ក្នុងពេល ១៣ ឆ្នាំកន្លងមកនេះ[23] បូករួម

[23] Kai Hauerstein, Assessment Report: Assessing the provision of legal aid and proposing policy recommendations, Final Draft, June 2018, pp. 51, 59.

ជាមួយការកើនឡើងនូវតម្រូវការការជួយជ្រោមជ្រែងផ្នែកច្បាប់បន្ថែមទៀតពីសហគមន៍ LGBTIQ ជាការបង្ហាញឱ្យឃើញថា ការកើនឡើងគួរជាទីកត់សម្គាល់នៃមូលនិធិជំនួយផ្នែកច្បាប់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងសហគមន៍ម្ចាស់ជំនួយ អាចជះឥទ្ធិពលដល់ជីវិតរបស់បុគ្គល LGBTIQ ក្នុងប្រទេសកម្ពុជា។

## សន្និដ្ឋាន

ថ្វីបើសំណុំរឿងពាក់ព័ន្ធជាមួយការរើសអើងផ្អែកលើ SOGIESC គឺជាសំណុំរឿងកម្រកើតមាន បើធៀបជាមួយបន្ទុកសំណុំរឿងទូទៅក្នុងតុលាការកម្ពុជាក្តី ប៉ុន្តែតម្រូវការដើម្បីបង្កើនលទ្ធភាពចូលទៅកាន់ប្រព័ន្ធយុត្តិធម៌ ជាពិសេសតាមរយៈជំនួយផ្នែកច្បាប់ គឺជាតម្រូវការដ៏ខ្លាំងមួយដើម្បីអាចសម្រេចបានសិទ្ធិរបស់សហគមន៍ LGBTIQ កម្ពុជា។ ទាំងអ្នកផ្តល់ចម្លើយក្នុងការស្ទាបស្ទង់មតិ និងអ្នកផ្តល់ព័ត៌មានគន្លឹះដែលត្រូវបានសម្ភាស បានគូសបញ្ជាក់អំពីស្ថានភាពដ៏គ្រោះថ្នាក់របស់បុគ្គល LGBTIQ នៅពេលត្រូវការការតស៊ូមតិទាមទារសិទ្ធិរបស់ខ្លួនក្នុងប្រព័ន្ធយុត្តិធម៌។ កង្វះចំណេះដឹងជាទូទៅរបស់សហគមន៍ LGBTIQ ស្តីអំពីលទ្ធភាពទទួលបានអ្នកតំណាងផ្នែកច្បាប់ក្នុងតម្លៃសមរម្យ គឺត្រូវបានដោះស្រាយដោយវិធានការបែបវិមជ្ឈការធ្វើឡើងដោយក្រសួងយុត្តិធម៌ និងការប្រាស្រ័យទាក់ទងកាន់តែច្រើនឡើងរវាងភាគីពាក់ព័ន្ធមកពីសង្គមស៊ីវិល។ ទោះយ៉ាងណាក្តី នៅតែមានចំណុចខ្វះចន្លោះដ៏ធំដែលចាំបាច់ត្រូវគ្របដណ្តប់ ដើម្បីធានាឱ្យបានថា ពុំមាននរណាម្នាក់ត្រូវបានទុកចោល ហើយសមាជិកគ្រប់រូបក្នុងសហគមន៍ LGBTIQ ដឹងពីទីកន្លែង និងរបៀបដើម្បីស្វែងរកជំនួយពេលពួកគេត្រូវការ។

យើងខ្ញុំសូមសង្កត់ធ្ងន់ថា ចំនួនជាក់លាក់នៃបញ្ហាដែលបានលើកឡើងនៅក្នុងរបាយការណ៍នោះ អាចត្រូវបានដោះស្រាយតាមរយៈការអនុម័តទៅលើសេចក្តីព្រាងច្បាប់ស្តីពីជំនួយផ្នែកច្បាប់។ យើងជឿជាក់ថា សេចក្តីព្រាងច្បាប់នេះ អាចបង្កើតឱ្យមានដំណើរការដែលងាយស្រួលចូលទៅរក និងងាយស្រួលយល់ ដើម្បីទទួលបានជំនួយផ្នែកច្បាប់សាធារណៈ ហើយនឹងអាចជួយលើកទឹកចិត្តសមាជិក LGBTIQ ឱ្យដាក់សំណុំរឿងរដ្ឋប្បវេណីទាក់ទងជាមួយសិទ្ធិរបស់ខ្លួនក្នុងការរៀបការ សិទ្ធិរបស់ខ្លួនក្នុងការទទួលស្គាល់យេនឌ័រ និងសិទ្ធិរបស់ពួកគេក្នុងការសុំកូន ដែលជាអាទិភាពខ្ពស់បំផុតទាំងបី ដែលសហគមន៍បានកំណត់ឃើញ។[24] អាទិភាពទាំងបីនេះ ក៏ជាបញ្ហាទាំងបីទាក់ទងជាមួយការប្រឆាំងការរើសអើង ដែលរាជរដ្ឋាភិបាលកម្ពុជាបានទទួលអនុសាសន៍ក្នុងអំឡុងពេលការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់ (UPR) របស់អង្គការសហប្រជាជាតិក្នុងជុំទីបី ហើយដែលអ្នកតំណាងរាជរដ្ឋាភិបាលកម្ពុជាបានសន្យាថា នឹងផ្តោតការយកចិត្តទុកដាក់នៅក្នុងរយៈពេល ៥ ឆ្នាំខាងមុខ។

ថ្វីបើផ្លូវធ្វើដំណើរនៅវែងឆ្ងាយក្តី ប៉ុន្តែយើងសង្ឃឹមថា សហគមន៍ LGBTIQ ក្នុងប្រទេសកម្ពុជា នឹងអាចបានទទួលអ្នកតំណាងក្នុងតម្លៃសមរម្យកាន់តែច្រើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ ប្រសិនបើភាគីពាក់ព័ន្ធទាំង

[24] Rainbow Community of Kampuchea, Research Report on Opinions, Attitudes and Behavior toward the LGBT population in Cambodia, op. cit.

អស់ រួមទាំងមូលនិធិសាធារណៈ និងមូលនិធិឯកជន នៅតែបន្តប្តេជ្ញាចិត្តធ្វើការជាមួយគ្នា។ យើងក៏ជឿជាក់ថា ការងារនេះ នឹងត្រូវបានសម្របសម្រួលដោយការអភិវឌ្ឍថ្មីៗថ្មោងនៃវប្បធម៌ការងារស្ម័គ្រចិត្តដោយឥតគិតថ្លៃពីមេធាវី ផងដែរ។

# ការរៀបធៀប៖ ការអនុវត្តល្អទូទាំងទ្វីបអាស៊ី

## ការផ្តួចផ្តើមគំនិតជំនួយផ្នែកច្បាប់សម្រាប់សហគមន៍ LGBTIQ ក្នុងតំបន់អាស៊ាន

នៅក្នុងតំបន់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (**អាស៊ាន**) ប្រទេសចំនួនប្រាំនៅតែចាត់ទុកការរួមភេទជាមួយមនុស្សមានភេទដូចគ្នាជាបទល្មើស រួមមានប្រទេសប្រ៊ុយណេ-ដារូសាឡឹម ឥណ្ឌូណេស៊ី ម៉ាឡេស៊ី មីយ៉ាន់ម៉ា និងសិង្ហបុរី។ ដូច្នេះ ថ្វីបើមានឆន្ទៈផ្នែកច្បាប់ក្នុងការរៀបចំជំនួយផ្នែកច្បាប់ក្នុងប្រទេសឥណ្ឌូណេស៊ី ម៉ាឡេស៊ី និងសិង្ហបុរីក្តី ប៉ុន្តែសហគមន៍ LGBTIQ ពុំបានទទួលអត្ថប្រយោជន៍ពីជំនួយទាំងអស់នេះឡើយទៅលើករណីពាក់ព័ន្ធជាមួយការរើសអើងផ្អែកលើ SOGIESC របស់ពួកគេ។ ក្នុងប្រទេសថៃ និងវៀតណាម លទ្ធភាពទទួលបានជំនួយផ្នែកច្បាប់របស់សហគមន៍ LGBTIQ គឺមានផ្តល់ជូនជាលក្ខណៈទ្រឹស្តី ដោយហេតុថា ប្រទេសទាំងពីរនេះគឺប្រទេសឈានមុខបំផុតលើបញ្ហា LGBTIQ ក្នុងតំបន់ ហើយមានវប្បធម៌ការងារស្ម័គ្រចិត្តឥតគិតថ្លៃ និងក្របខ័ណ្ឌការងារជំនួយផ្នែកច្បាប់។

**មីយ៉ាន់ម៉ា**

ពុំមានជំនួយផ្នែកច្បាប់ត្រឹមត្រូវទេ ប៉ុន្តែមានវប្បធម៌ការងារស្ម័គ្រចិត្តឥតគិតថ្លៃ។

ការផ្តួចផ្តើមគំនិតជាឯកជន៖

មីយ៉ាន់ម៉ាពណ៌ឥន្ទធនូ មានបណ្តាញទូរសព្ទទាន់ហេតុការណ៍ ដោយមានអ្នកប្រកបវិជ្ជាជីវៈអមអាជីពច្បាប់ ដែលអាចផ្តល់ការចង្អុលបង្ហាញ និងការជួយជ្រោមជ្រែងដល់បុគ្គល LGBTIQ។

**ហ្វីលីពីន**

ជំនួយផ្នែកច្បាប់ត្រូវបានផ្តល់ឱ្យតាមរយៈ "ច្បាប់ស្តីពីការជួយជ្រោមជ្រែងផ្នែកច្បាប់ដោយឥតគិតថ្លៃឆ្នាំ ២០១០" ថ្វីបើច្បាប់នេះ ពុំមានការលើកឡើងជាក់លាក់អំពីសហគមន៍ LGBTIQ ក្តី។

អង្គការសង្គមស៊ីវិលផ្តល់ជំនួយផ្នែកច្បាប់ដល់ LGBTIQ៖

គម្រោងសិទ្ធិឥន្ទធនូ។



**សិង្ហបុរី**

ជំនួយផ្នែកច្បាប់ត្រូវបានផ្តល់ឱ្យតាមរយៈច្បាប់ស្តីពីជំនួយផ្នែកច្បាប់ និងដំបូន្មានផ្នែកច្បាប់ (LAAA) ជំពូក ១៦០។

ការផ្តួចផ្តើមគំនិតឯកជន៖

*-ដូចគ្នាប៉ុន្តែខុសគ្នា៖ សៀវភៅណែនាំផ្នែកច្បាប់សម្រាប់គូស្រករ និងគ្រួសារ LGBT ក្នុងប្រទេសសិង្ហបុរី* ដែលត្រូវបានបង្កើតឡើងដោយក្រុមការងារមេធាវីសិង្ហបុរីមួយក្រុម ដើម្បីជួយដល់សហគមន៍ LGBTIQ ក្នុងការបង្ហាញទិសអំពីច្បាប់ និងទទួលបានការការពារមួយចំនួន បើទោះបីជាច្បាប់នៅតែចាត់ទុកការរួមភេទជាមួយមនុស្សមានភេទដូចគ្នាជាបទល្មើសក្តី។

*Map by Surassawadee, Royalty-free stock vector images, ID: 152408471 sketch ASEAN Map, Vector illustration -*

## ការផ្តួចផ្តើមគំនិតជំនួយផ្នែកច្បាប់សម្រាប់សហគមន៍ LGBTIQ ក្នុងតំបន់អាស៊ីប៉ូស៊ីហ្វិក

ការផ្តួចផ្តើមគំនិតចំនួនបីដូចមានគូសបញ្ជាក់ខាងក្រោម គឺមានលក្ខណៈប្រហាក់ប្រហែលជាមួយការផ្តួចផ្តើមគំនិតបង្កើតឡើងដោយប្រទេសសិង្ហបុរី និងពឹងផ្អែកលើមេធាវី ច្រើនជាងលើរដ្ឋាភិបាល ឬការផ្តួចផ្តើមគំនិតជំរុញដោយអង្គការក្រៅរដ្ឋាភិបាល។

**សាធារណរដ្ឋប្រជាមានិតចិន**

- **បណ្តាញទូរសព្ទទាន់ហេតុការណ៍សៀងហៃសម្រាប់ជនភាគតិចផ្នែកភេទ** បានចាប់ផ្តើមក្នុងឆ្នាំ ២០០៣ ដោយ Zhou Dan ដែលជាមេធាវីបុរសស្រលាញ់ភេទដូចគ្នាដោយបើកចំហតែម្នាក់គត់ ក្នុងការជួយដល់សហគមន៍ LGBTIQ ក្នុងប្រទេសចិន តាមរយៈការផ្តល់ជំបូន្មានផ្នែកច្បាប់ដោយឥតគិតថ្លៃ។

**ហុងកុង**

- **បណ្តាញមេធាវី LGBT+ ហុងកុង (HKGALA)** មានបំណងដើម្បីលើកកម្ពស់នានាភាពរបស់ LGBTIQ និងការរួមបញ្ចូលនៅក្នុងវិជ្ជាជីវៈអាជីពផ្នែកច្បាប់ បង្កើនការយល់ដឹងអំពីបញ្ហាផ្នែកច្បាប់របស់ LGBTIG នៅក្នុងដែនដីហុងកុង និងបរទេស ក៏ដូចជាលើកទឹកចិត្តដោយមានការងារស្ម័គ្រចិត្តឥតគិតថ្លៃផ្តោតការយកចិត្តទុកដាក់លើ LGBT។ គិត្រឹមខែកុម្ភៈ ឆ្នាំ២០១៩ បណ្តាញនេះរួមមានក្រុមហ៊ុនដែលផ្តល់ការគាំទ្រជាង៥០ និងមានសមាជិក និងអ្នកគាំទ្រជាបុគ្គលជាង ៧០០ នាក់។

**ជប៉ុន**

- **បណ្តាញសម្ព័ន្ធមិត្តមេធាវីសម្រាប់ LGBT** គឺជាអង្គភាពផ្នែកច្បាប់ បង្កើតឡើងដើម្បីលើកកម្ពស់ការយល់ដឹងអំពីLGBTIQ និងលុបបំបាត់ការរើសអើងផ្អែកលើ SOGIESC តាមរយៈការផ្តល់ការជួយជ្រោមជ្រែងផ្នែកច្បាប់ដល់សហគមន៍ទាំងអស់នេះ។

ការផ្តួចផ្តើមគំនិតដែលត្រូវបានអភិវឌ្ឍឡើងក្នុងតំបន់អាស៊ាន និងអាស៊ីប៉ូស៊ីហ្វិក អាចដើរតួនាទីជាឧទាហរណ៍អំពីការអនុវត្តល្អ ដែលអាចកែសម្រួលឱ្យសមស្របតាមបរិបទកម្ពុជា។ បន្ថែមលើនេះទៀត បណ្តាប្រទេសអាស៊ីប៉ូស៊ីហ្វិកដែលត្រូវបានជ្រើសរើសនៅទីនេះ គឺត្រូវបានគេស្គាល់ថាជាម្ចាស់ជំនួយ និង/ឬជាអ្នកផ្តល់ការជួយជ្រោមជ្រែងផ្នែកបច្ចេកទេសដល់រាជរដ្ឋាភិបាលកម្ពុជានៅក្នុងប្រព័ន្ធផ្នែកច្បាប់ និងយុត្តិធម៌ អមជាមួយនឹងមេធាវីឯកជនមួយចំនួន ក៏កំពុងប្រកបវិជ្ជាជីវៈអាជីពក្នុងប្រទេសកម្ពុជាផងដែរ។ ទោះយ៉ាងណាក្តី ការអនុវត្តល្អ និងការផ្តួចផ្តើមគំនិតល្អៗទាំងនោះ ពុំត្រូវបានស្រាវជ្រាវអោយបានជិតដល់ឡើយ ហើយផ្តោតការយកចិត្តទុកដាក់លើបណ្តាប្រទេសជិតប៉ុណ្ណោះ។ យើងជឿជាក់ថា មានការអនុវត្តល្អៗដទៃទៀតជាច្រើនក្នុងពិភពលោក ដែលអាចយកមកកែសម្រួលឱ្យត្រូវបានបរិបទប្រទេសកម្ពុជា។

# អនុសាសន៍សរុបសេចក្តី

អនុសាសន៍សរុបសេចក្តីរបស់អង្គការគោលដៅយុត្តិធម៌ មានប្រភពចេញមកពីការពិចារណាជាមូលដ្ឋានចំនួនពីរ៖

- ដើម្បីបង្កើនការប្រាស្រ័យទាក់ទងក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់ ដែលធ្វើការងារជុំវិញប្រធានបទជំនួយផ្នែកច្បាប់សម្រាប់សហគមន៍ LGBTIQ ក្នុងប្រទេសកម្ពុជា តាមរយៈការបង្កើត/ជំរុញបណ្តាញកិច្ចពិភាក្សាដែលមានស្រាប់ រួមមានដូចជារាជរដ្ឋាភិបាលកម្ពុជា ស្ថាប័នអង្គការសហប្រជាជាតិ មេធាវី និងអង្គការសង្គមស៊ីវិល
- ដើម្បីធានាឱ្យបានថា សហគមន៍ LGBTIQ មានលទ្ធភាពទទួលបានព័ត៌មានស្តីពីសេវាផ្នែកច្បាប់ក្នុងប្រទេសកម្ពុជា ជាពិសេសពាក់ព័ន្ធទៅនឹងជំនួយផ្នែកច្បាប់តាមរយៈការផ្សព្វផ្សាយព័ត៌មានសព្វជ្រុងជ្រោយ និងមានបច្ចុប្បន្នភាព។

អនុសាសន៍ខាងក្រោម ផ្តោតជាចំពោះសម្រាប់រាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័នរបស់ខ្លួន។

## អនុសាសន៍ចំពោះរដ្ឋាភិបាលកម្ពុជា

- ឈានទៅអនុម័តឱ្យទាន់ពេលវេលា និងធានាឱ្យមានការអនុវត្តច្បាប់ស្តីពីជំនួយផ្នែកច្បាប់ ជាពិសេស គឺសម្រាប់ក្រុមងាយរងគ្រោះ
- បន្តឈានទៅសម្រេចឱ្យបានកិច្ចខិតខំក្នុងការបង្កើនថវិកាសម្រាប់ជំនួយផ្នែកច្បាប់ ដើម្បីធានាឱ្យបានថា ពុំមានរណាម្នាក់ត្រូវបានទុកចោល ជាពិសេសគឺសហគមន៍ LGBTIQ
- ផ្តល់វគ្គបណ្តុះបណ្តាលពាក់ព័ន្ធនឹងបញ្ហា SOGIESC ជូនដល់អ្នកប្រកបវិជ្ជាជីវៈអាជីពផ្នែកយុត្តិធម៌ទាំងអស់ក្នុងប្រទេសកម្ពុជា ជាពិសេស គឺមេធាវី និងមន្ត្រីរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន ដោយធ្វើឡើងតាមរយៈក្រសួងយុត្តិធម៌ និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

## អនុសាសន៍ចំពោះក្រុមហ៊ុនមេធាវី និងមេធាវី

- ចូលរួមក្នុងវគ្គបណ្តុះបណ្តាលជាប្រចាំស្តីពីបញ្ហាផ្នែកច្បាប់ក្នុង SOGIESC ផ្តល់ដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បន្តអភិវឌ្ឍវប្បធម៌ការងារស្ម័គ្រចិត្តដោយឥតគិតថ្លៃ ដោយផ្តោតការយកចិត្តទុកដាក់លើជនងាយរងគ្រោះពិសេស គឺអ្នកស្រលាញ់ភេទដូចគ្នា LGBTIQ

– សម្របសម្រួលជាមួយអង្គការសង្គមស៊ីវិល ដែលធ្វើការលើបញ្ហាជំនួយផ្នែកច្បាប់ និង/ឬបញ្ហា LGBTIQ ហើយជួយជ្រោមជ្រែងនៅក្នុងការអភិវឌ្ឍមគោលនយោបាយ/យន្តការ ដើម្បីធានាឱ្យបានថាអ្នកស្រលាញ់ភេទដូចគ្នា(LGBTIQ) ទទួលបានដំបូន្មានផ្នែកច្បាប់សមស្រប។

## អនុសាសន៍ចំពោះអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា

– ដឹកនាំ និងជួយជ្រោមជ្រែងដល់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការអភិវឌ្ឍវគ្គបណ្តុះបណ្តាលស្តីពីបញ្ហាផ្នែកច្បាប់ស្តីអំពី SOGIESC សម្រាប់មេធាវីក្នុងប្រទេសកម្ពុជា។

## អនុសាសន៍ចំពោះម្ចាស់ជំនួយ

– ផ្តល់ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងនាពេលបច្ចុប្បន្ន ក្នុងការកែលម្អលទ្ធភាពទទួលបានជំនួយផ្នែកច្បាប់សម្រាប់សហគមន៍ LGBTIQ ក្នុងប្រទេសកម្ពុជា តាមរយៈការផ្តល់យ៉ាងហោចណាស់ឱ្យមានមូលនិធិគ្រប់គ្រាន់ ដើម្បីគ្របដណ្តប់លើសំណុំរឿងដែលនៅសេសសល់ទាំងអស់។

## អនុសាសន៍ចំពោះសង្គមស៊ីវិល

– បង្កើតមូលនិធិពិសេសសម្រាប់ជំនួយផ្នែកច្បាប់ក្នុងសំណុំរឿង LGBTIQ ដើម្បីគាំទ្រដល់កិច្ចខិតខំផ្នែកការតស៊ូមតិ និងលើកកម្ពស់សិទ្ធិ LGBTIQ ក្នុងប្រទេសកម្ពុជា
– ដើម្បីដាក់សំណុំរឿងយុត្តិធម៌ LGBTIQ នៅថ្នាក់កណ្តាល ក្នុងបំណងដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការជាមួយមេធាវីនានា តាមរយៈការបង្កើតឱ្យមាននីតិវិធីប្រាស្រ័យទាក់ទង និងនីតិវិធីបញ្ជូនដែលមានលក្ខណៈច្បាស់លាស់ និងសព្វជ្រុងជ្រោយ។

# ឧបសម្ព័ន្ធទី ១ ៖ គម្រូខសំណួរ

**ជំនួយផ្នែកច្បាប់ & ក្រុមអ្នកស្រលាញ់ភេទដូចគ្នានៅប្រទេសកម្ពុជា**

ការស្ទាប់ស្ទង់មតិមួយនេះ គឺជាផ្នែកមួយនៃកិច្ចការស្រាវជ្រាវ ដែលធ្វើឡើងដោយអង្គការគោលដៅយុត្តិធម៌ ក្រោមកិច្ចគាំទ្ររបស់សហភាពអឺរ៉ុប ក្នុងគម្រោងសម្លេងយែនឌ័រនៅក្នុងប្រទេសកម្ពុជា។

ការស្ទង់មតិ មានគោលដៅបន្លិចឡើងនូវ ភាពដែលក្រុមអ្នកស្រលាញ់ភេទដូចគ្នាគ្រប់រូបអាចប្រើប្រាស់សេវាយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា តាមរយៈជំនួយផ្នែកច្បាប់។

ទិន្នន័យទាំងអស់ដែលប្រមូលបាន មានគោលដៅសម្រាប់តែកិច្ចការស្រាវជ្រាវប៉ុណ្ណោះ ហើយឈ្មោះនឹងត្រូវបានរក្សាជាការសម្ងាត់។

ការស្ទង់មតិចំណាយត្រឹមតែ ៥ នាទីប៉ុណ្ណោះ ក្នុងការបំពេញ។

ក្រុមការងារយើងខ្ញុំសូមកោតសរសើរយ៉ាងជ្រាលជ្រៅចំពោះការចូលរួមក្នុងកិច្ចការស្រាវជ្រាវរបស់ពួកយើង។

សូមថ្លែងអំណរគុណ!

អង្គការគោលដៅយុត្តិធម៌

Email Address *

…………………………………………………………….

**1. អំពីអ្នក**

មុននឹងចាប់ផ្តើមការស្ទាប់ស្ទង់មតិ យើងសុំការអនុញ្ញាតដឹងពីពត៌មានបន្ថែមបន្តិចទៀតអំពីអ្នករាល់គ្នា

តើអ្នកឈ្មោះអ្វី? *

…………………………………………………………….

តើអ្នកអាយុប៉ុន្មាន? *

…………………………………………………………….

តើអ្នកកំពុងរស់នៅឯណា? (សូមបញ្ជាក់អំពី ក្រុង/ខេត្ត) *

…………………………………………………………….

តើអ្នកមានយែនឌ័រអ្វី? *

- ○ ស្រី
- ○ ប្រុស
- ○ អ្នកប្តូយែនឌ័រ (នារី)

- អ្នកប្តូរយេនឌ័រ (បុរស)
- មិនចង់បង្ហាញប្រាប់
- ផ្សេងៗ

តើអ្នកមាននិន្នការភេទជាអ្វី? *

- ស្រីស្រលាញ់ស្រី
- ប្រុសស្រលាញ់ប្រុស
- ស្រាញ់ប្រុសផង ស្រីផង
- ស្រលាញ់ភេទផ្ទុយគ្នា
- មិនចង់បង្ហាញ

**2. ការទទួលបានមេធាវី**

យើងខ្ញុំចង់ដឹងបន្ថែមទៀតពីអ្នកទាំងអស់គ្នា ទាក់ទងនឹងកម្រិតនៃការទទួលបានសេវាពីអ្នកជំនាញផ្នែកច្បាប់

តើអ្នកធ្លាប់សុំជំនួយមេធាវីឬទេ? *

- បាទ/ចាស
- ទេ
- ខ្ញុំមិនចាំទេ
- មិនចង់បង្ហាញ

តើអ្នកបានរកមេធាវីនៅឯណា? *

- ក្រសួងយុត្តិធម៌
- គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- សេវាជំនួយផ្នែកច្បាប់
- សមាគមន៍អាដហុក
- មជ្ឈមណ្ឌលសិទ្ធិមនុស្សនៅកម្ពុជា
- លីកាដូ
- អង្គការស្តោនយុត្តធម៌កម្ពុជា
- ក្រុមហ៊ុនមេធាវីឯកជន
- ផ្សេងៗ

តើអ្នកបានប្រាប់ទៅកាន់មេធាវីដែរទេពី និន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់អ្នកដែរឬទេ? *

- បាទ/ ចាស
- ទេ
- ខ្ញុំមិនចាំទេ
- មិនចង់បង្ហាញ
- ផ្សេងៗ

ហេតុអ្វីបានជាអ្នកមិនប្រាប់ពី និន្និការភេទ និងអត្តសញ្ញាណយេនឌ័ររបស់អ្នកទៅកាន់មេធាវី? *

- ដោយហេតុតែខ្លាចថានឹងត្រូវគេរើសអើង
- វាមិនទាក់ទងនឹងរឿងក្តី
- ខ្ញុំមិនបានគិតពីថាត្រូវប្រាប់ឬមិនប្រាប់ទេ
- ផ្សេងៗ

**3. ចំណេះដឹងលើជំនួយផ្នែកច្បាប់**

ជំនួយផ្នែកច្បាប់ គឺជាប្រើប្រាស់មូនិធិរបស់រដ្ឋ ដើម្បីជួយចំណាយទៅលើ ការអោយយោបល់ផ្នែកច្បាប់ ឬសម្រាប់ដំណើរការក្តីដែលតម្រូវអោយមានមេធាវីការពារ ហើយគ្មានលទ្ធភាពក្នុងការជួលមេធាវីបាន។

តាមរយៈនិយមន័យខាងលើ តើអ្នកយល់ថាអ្វីទៅជាជំនួយផ្នែកច្បាប់? *
ដាក់លំដាប់ពី ១ ទៅ ៥ (១ អត់យល់សោះ, 5 យល់ច្បាស់)

កាលពីមុនមក តើអ្នកធ្លាប់ទទួលបានពត៌មានទាក់ទងនឹងជំនួយផ្នែកច្បាប់ឬទេ? *

- មិនដែលទទួលបានសោះ
- យូរៗបានទទួលម្តង
- ជួនបានជួនអត់
- ទទួលបានជាញឹកញាប់
- តែងតែទទួលបាន

តើអ្នកយល់ថា អ្នកអាចនឹងទទួលបានសេវាជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃដែរឬទេ ប្រសិនបើអ្នកត្រូវការជំនួយមេធាវី? *

ដាក់លំដាប់ពី ១ ទៅ ៥ (១ មិនអាច, 5 អាច)

តើអ្នកជឿទុកចិត្តមេធាវីដែលផ្តល់សេវាឥតគិតថ្លៃដែរឬទេ ? *

ដាក់លំដាប់ពី ១ ទៅ ៥ ( ១ ទុកចិត្ត, 5 មិនទុកចិត្ត )

តើអ្នកស្គាល់មេធាវីដែលផ្តល់សេវាឥតគិតថ្លៃសម្រាប់ក្រុមអ្នកស្រលាញ់ភេទដូចគ្នាដែរឬទេ ? *

- ○ បាទ/ចាស
- ○ ទេ
- ○ ខ្ញុំមិនដឹងទេ

តើអ្នកដឹងទេថា មេធាវីដែលផ្តល់សេវាឥតគិតថ្លៃ ធ្វើនៅក្នុងស្ថាប័នណាមួយក្នុងចំណោចស្ថាប័នខាងក្រោម ? *

- ○ ខ្ញុំមិនដឹងទេ
- ○ ក្រសួងយុត្តិធម៌
- ○ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- ○ សេវាជំនួយផ្នែកច្បាប់
- ○ សមាគមន៍អាដហុក
- ○ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
- ○ អង្គការលីកាដូ
- ○ អង្គការស្ថានយុត្តិធម៌កម្ពុជា
- ○ សមាគមន៍ឥន្ទធនូកម្ពុជា
- ○ ផ្សេងៗ

**4- ទំនាក់ទំនងរវាងអ្នក និងជំនួយផ្នែកច្បាប់**

តើអ្នកធ្លាប់ស្នើសុំជំនួយផ្នែកច្បាប់ឬទេ ? *

- ○ បាទ/ចាស
- ○ ទេ
- ○ ញុំមិនចាំទេ
- ○ មិនចង់បង្ហាញ

ប្រសិនបើអ្នកបានទទួលជំនួយផ្នែកច្បាប់ តើរឿងក្តីនោះ មានជាប់ទាក់ទងជាមួយនឹងការរើសអើងខាង និន្នាការភេទ និងអត្តសញ្ញាណយែនឌ័រឬទេ ? *

- បាទ /ចាស
- ទេ
- ខ្ញុំមិនចាំទេ
- មិនចង់បង្ហាញ
- ផ្សេងៗ

ប្រសិនបើអ្នកធ្លាប់ទទួលបានជំនួយផ្នែកច្បាប់ តើអ្នកពេញចិត្តនឹងកិច្ចការពារពីមេធាវីដែរឬទេ ? *
ដាក់លំដាប់ពី ១ ទៅ ៥ ( ១ មិនពេញចិត្ត, 5 ពេញចិត្ត )

ប្រសិនបើមិនបានទទួល តើរឿងក្ដីបានដំណើរការទៅមុខដែរឬទេ ?

- បាន/ ចាស ៖ ខ្ញុំមានលុយគ្រប់គ្រាន់ដើម្បីជួលមេធាវី
- បាទ/ចាស ៖ គ្រួសារ និងមិត្តភក្តិជួយខ្ញុំក្នុងការបង់ថ្លៃ
- បាទ/ចាស ៖ មេធាវីការពារក្ដីឥតគិតថ្លៃ
- បាទ/ចាស៖ អង្គការមួយបានជួយខ្ញុំ
- អត់ទេ / ខ្ញុំគ្មានលុយគ្រប់គ្រាន់សម្រាប់ជួលមេធាវី ហើយខ្ញុំសម្រេចបោះបង់ចោលសំណុំរឿង
- អត់ទេ ៖ ខ្ញុំកំពុងតែត្រូវស្វែងរកលុយ
- ញុំមិនចាំនោះទេ
- មិនចង់បង្ហាញ
- ផ្សេងៗ

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះ ពុំអាចកើតចេញជារូបរាងបានទេ ប្រសិនបើពុំមានការចូលរួមវិភាគទានកាត់ថ្លៃមិនបានពីអ្នកស្រលាញ់ភេទដូចគ្នា(LGBTIQ) ទូទាំងប្រទេសកម្ពុជា រួមទាំងអ្នកផ្តល់ចម្លើយក្នុងការស្ទាបស្ទង់មតិរបស់យើង ព្រមទាំងអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលយើងបានជ្រើសរើសរក្សាអត្តសញ្ញាណរបស់ពួកគេ ឱ្យនៅជាអនាមិក។

ការស្រាវជ្រាវដែលត្រូវបានបង្ហាញជូនក្នុងរបាយការណ៍នេះ ត្រូវបានធ្វើឡើងក្រោមការគាំទ្ររបស់គម្រោងសំឡេងយេនឌ័រតាមរយៈ DanChurchAid (DCA) និងសហគមន៍អឺរ៉ុប (EU)។ អង្គការគោលដៅយុត្តិធម៌ ក៏សូមថ្លែងអំណរគុណចំពោះសហគមន៍ឥន្ទធនូកម្ពុជា(RoCK) ដែលផ្តល់កិច្ចគាំទ្រជាបន្តបន្ទាប់របស់ពួកគេ មិនត្រឹមតែសម្រាប់របាយការណ៍នេះតែប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់គម្រោងយុត្តិធម៌ឥន្ទធនូថែមទៀតផងដែរ។

របាយការណ៍នេះ ត្រូវបានផលិតឡើងដោយអង្គការគោលដៅយុត្តិធម៌។ អ្នកចូលរួមវិភាគទានសំខាន់ៗ រួមមាន Céline Martin, Puy Suo, Remicard Sereme និង Doreen Chen។

ក្នុងប្រទេសកម្ពុជា បើទោះបីជាមិនមានការដាក់ទោសទណ្ឌដោយផ្អែកលើនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញនូវទំនោរយេនឌ័រ និងលក្ខណៈភេទ (SOGIESC) របស់ពួកគេក្តី ប៉ុន្តែពុំមានការពារតាមផ្លូវច្បាប់ណាមួយឡើយ ហើយក៏ពុំមានការបញ្ជ្រាបចំណេះដឹងអំពី LGBTIQ ឬ SOGIESC ដាក់លាក់តាមរយៈការបណ្តុះបណ្តាលដល់អ្នកប្រកបវិជ្ជាជីវៈផ្នែកតុលាការ ឬមន្ត្រីនគរបាលនោះដែរ។ យើងអាចនិយាយម្យ៉ាងទៀតថា ប្រព័ន្ធយុត្តិធម៌មានភាពស្ងាត់ស្ងៀមនៅពេលនិយាយអំពីបុគ្គល LGBTIQ បើទោះបីជាសហគមន៍នេះ ជួបប្រទះនូវភាពងាយរងគ្រោះផ្នែកសង្គម និងសេដ្ឋកិច្ចយ៉ាងណាក្តី។ ជាលទ្ធផល បុគ្គល LGBTIQ ជារឿយៗតែងធ្លាក់ខ្លួនទៅក្នុងស្ថានភាពដ៏អាក្រក់ពេលដែលពួកគេព្យាយាមចូលទៅរកប្រព័ន្ធ យុត្តិធម៌កម្ពុជា ដោយត្រូវពឹងផ្អែកលើអង្គការសង្គមស៊ីវិល (CSOs) តែមួយចំនួនតូចប៉ុណ្ណោះដែលកំពុងផ្តល់ដំបូន្មានផ្នែកច្បាប់ដោយឥតគិតថ្លៃ និង/ឬមេធាវីតិចតួចបំផុតដែលផ្តល់សេវាមិនយកកម្រៃ.

ដូចនេះហើយ របាយការណ៍បានធ្វើការមើលទៅលើចំណេះដឹងរបស់សហគមន៍ LGBTIQ ពាក់ព័ន្ធទៅនឹងកន្លែង និងរបៀបដែលពួកគេអាចមានលទ្ធភាពក្នុងការទទួលបានការតំណាងផ្នែកច្បាប់ដោយឥតគិតថ្លៃ ឬមានតម្លៃសមរម្យ ទាក់ទងនឹងបរិបទ និងការយល់ដឹងខាងផ្នែកជំនួយផ្នែកច្បាប់សម្រាប់សហគមន៍អ្នកស្រលាញ់ភេទដូចគ្នា និងបទពិសោធន៍របស់សមាជិកនៃសហគមន៍។

ជំនួយផ្នែកច្បាប់ឥន្ទធនូ គឺជាផ្នែកនៃគម្រោងយុត្តិធម៌ឥន្ទធនូ របស់អង្គការគោលដៅយុត្តិធម៌។ តាមរយៈគម្រោងយុត្តិធម៌ឥន្ទធនូ អង្គការគោលដៅយុត្តិធម៌ មានគោលបំណងជំរុញកិច្ចសន្ទនានៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ជាពិសេសក្នុងប្រទេសកម្ពុជា ទាក់ទងនឹង និន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញនូវទំនោរយេនឌ័រ និងលក្ខណៈភេទ (SOGIESC) និងផ្តល់មធ្យោបាយតស៊ូមតិដល់អ្នកធ្វើការផ្លាស់ប្តូរ ដើម្បីលើកកម្ពស់ និងការពារសិទ្ធិរបស់សហគមន៍ស្ត្រីស្រលាញ់ភេទដូចគ្នា បុរសស្រលាញ់ភេទដូចគ្នា អ្នកស្រលាញ់ភេទទាំងពីរ អ្នកប្តូរភេទ អ្នកអន្តរភេទ និងអ្នកមានភេទមិនកំណត់ច្បាស់ (LGBTIQ)។

គោលដៅយុត្តិធម៌

DESTINATION JUSTICE

www.destinationjustice.org